# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១ ថ្ងៃទី០១-៣១ ខែឧសភា ឆ្នាំ២០០៨ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ **លេខ ០៩**


ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

## មាតិកា




**សិក្ខាសាលាពង្រឹងសមត្ថភាពគ្រូអប់រំបន្តជំនឿ** ទំព័រ ៧



**ចូលរួមលើកកម្ពស់ភាពជាសហគ្រិនសម្រាប់យុវជន** ទំព័រ ៨



**ខួបកំណើតជាចម្រើនព្រះជន្ម?** ទំព័រ ១៤


# ខ្មែរមកពីបរទេស និងការអភិវឌ្ឍន៍ប្រទេសកម្ពុជា

ទំព័រទី១០...







កម្មវិធីវិទ្យុ



**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !

**ភ្នំពេញ : FM 99.5 Mhz** ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍
**បាត់ដំបង : FM 91.0 Mhz** ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍
**សៀមរាប : FM 102.5 Mhz** ១០:០០-១០:៣០ ថ្ងៃ សៅរ៍/អាទិត្យ
**កំពង់ធំ : FM 88.5 Mhz** ម៉ោង ១២:០០-១២:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
**កំពង់ចាម : FM 100.5 Mhz** ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
**ក្រុងព្រះសីហនុ : FM 100.5 Mhz** ម៉ោង៧:៣០-៨:០០ យប់ថ្ងៃសៅរ៍
**កំពត : FM 92.25 Mhz** ម៉ោង ១២:០០-១២:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់

April-2008.qxd 5/2/2008 11:28 AM Page 2

# រូបថតសម្រាប់ខែនេះ



Photo : Caritas

អគ្គិភ័យបានឆាបឆេះផ្ទះនៅម្តុំសំណង់អនាធិបតេយ្យបឹងកំប្លោក ទល់មុខមន្ទីរពេទ្យព្រះកុសុមៈ ហៅពេទ្យលោកសង្ឃ រាជធានីភ្នំពេញ កាលពីថ្ងៃសុក្រទី១១ ខែមេសា ឆ្នាំ២០០៨។ ភ្លើងឆេះបំផ្លាញផ្ទះប្រហែល ៩៥០ខ្នង ដែលភាគច្រើនអ្នកក្រីក្ររស់នៅ។ នេះជាអគ្គិភ័យធំបំផុតក្នុងឆ្នាំនេះ។**(ឆ្វេង)**

បាតុកម្មអហិង្សារៀបចំដោយគណបក្សប្រឆាំងកាលពីថ្ងៃ០៦ មេសា ទាមទារឱ្យរដ្ឋាភិបាលបញ្ចុះពន្ធលើប្រេងសាំង បញ្ចុះប្រាក់ចំណេញសម្រាប់ក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈ បញ្ចប់អាជីវកម្មសិទ្ធិផ្តាច់មុខ និងគ្រប់គ្រងសេដ្ឋកិច្ចជាតិឱ្យប្រសើរ-ល-។ **(ក្រោម)**



Photo : L. Sovanna

ការរំឭកពាក្យសច្ចារបស់បុព្វជិតានៃក្រុមអ្នកស្រឡាញ់ឈើឆ្កាងកាលពីល្ងាចថ្ងៃទី២៦ ខែមីនា នៅព្រះសហគមន៍កាតូលិកខេត្តកំពង់ចាម។ បុព្វជិតាខ្មែរដែលជាសមាជិកនៃក្រុមអ្នកស្រឡាញ់ឈើឆ្កាងមានបីរូប គឺបងស្រីអាង សង្វាត និងបងស្រីសួន ប៊ុនថារីននៅព្រះសហគមន៍ព្រៃវែង និងបងស្រីសុជាតិនៅក្រចេះ។ **(ក្រោម)**



Photo : Damo

តារាងតម្លៃបញ្ជាក់ថាអង្កររដ្ឋលក់ថោកៗ ដែលប្រជាពលរដ្ឋអាចស្វែងរកទិញបាននៅតាមទីផ្សារមួយចំនួននៅភ្នំពេញ ដូចជាផ្សារអូរឫស្សី ផ្សារអូរឡាំពិក ផ្សារចាស់ ឬផ្សារដើមគ-ល-។ **(ក្រោម)**



Photo : L. Sovanna

ឆ្នាំនេះទីផ្សារអង្ករពិភពលោកបានកើនតម្លៃយ៉ាងខ្លាំង។ នៅកម្ពុជា រាជរដ្ឋាភិបាលបានបញ្ចេញអង្ករពីក្នុងស្តុករបស់ខ្លួន លក់ក្នុងតម្លៃថោកដើម្បីសម្រាលការលំបាករបស់ប្រជាពលរដ្ឋ លើសពីនេះរដ្ឋបិទការនាំចេញអង្ករទៅបរទេសរយៈពេលពីរខែផងដែរ។ **(ឆ្វេង)**




Photo : L. Sovanna



# វិចារណកថា

## សន្តិភាព និងការវិលត្រឡប់មកអភិវឌ្ឍ



Photo : P. Samphy

លោកបូជាចារ្យ
អូមែរ ហ្សឺរ៉ាល់ដូ
ប្រធានមណ្ឌលផ្សព្វផ្សាយ
ព័ត៌មានកាតូលិក (CSC)

អង្គការសហប្រជាជាតិបានឱ្យនិយមន័យ វប្បធម៌សន្តិភាពជា "បណ្តុំនៃតម្លៃចរិតលក្ខណៈ អាកប្បកិរិយា និងជារបៀបរស់នៅមួយដែលគ្មានអំពើហិង្សា គ្មានជម្លោះ ហើយនិងចេះដោះស្រាយបញ្ហាដោយសន្តិវិធីតាមរយៈការពិភាក្សាគ្នា និងការចរចាគ្នារវាងបុគ្គល និងបុគ្គល ក្រុម និងក្រុម ឬមួយរវាងជាតិសាសន៍មួយ និងជាតិសាសន៍ដទៃទៀត"។

ចាប់តាំងពីមានសន្ធិសញ្ញាសន្តិភាពឆ្នាំ១៩៩១ ប្រទេសកម្ពុជាក៏បាននឹងកំពុងខិតខំប្រឹងប្រែងជាខ្លាំង ដើម្បីកសាងវប្បធម៌សន្តិភាព ដោយមានការចូលរួមជួយឧបត្ថម្ភ និងគាំទ្រយ៉ាងខ្លាំងពីសំណាក់សហគមន៍អន្តរជាតិនានា។

រដ្ឋាភិបាលកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាល កំពុងខិតខំប្រឹងប្រែង និងមានបំណងយ៉ាងខ្លាំងដើម្បីអភិវឌ្ឍផ្នែកសំខាន់ៗរួមមានប្រព័ន្ធអប់រំឱ្យមានការរីកចម្រើន លើកកម្ពស់សិទ្ធិស្ត្រី និងកុមារ បង្កើននូវសេរីភាពសារព័ត៌មាន និងពន្លឿនកំណើនសេដ្ឋកិច្ចដោយសមធម៌-ល-។ ផ្អែកលើចក្ខុវិស័យនេះប្រជាជនកម្ពុជា ដែលបានចាកចេញពីប្រទេសខ្មែរអស់រយៈពេល ៣ ទសវត្សរ៍ ក្នុងនាមជនភៀសខ្លួន កំពុងតែវិលត្រលប់មកស្រុកកំណើតវិញ ដោយមានការជឿជាក់ដើម្បីចូលរួមធ្វើការអភិវឌ្ឍន៍ប្រទេសប្រកបដោយសេចក្តីថ្លៃថ្នូរ កិត្តិយស ការគោរព និងដោយសេចក្តីស្រលាញ់គ្នាទៅវិញទៅមក។ ការជឿជាក់ពីប្រជាជនទាំងក្នុង និងក្រៅប្រទេស ជាកត្តាយ៉ាងសំខាន់ដើម្បីកសាងវប្បធម៌សន្តិភាពនៅក្នុងសង្គមកម្ពុជា។

អ្វីដែលសំខាន់សម្រាប់មនុស្សជំនាន់ក្រោយជាពិសេសយុវវ័យ គឺត្រូវមានការយល់ដឹងអំពីច្បាប់ សេរីភាព ស្រលាញ់យុត្តិធម៌ លទ្ធិប្រជាធិបតេយ្យ គោរពសិទ្ធិមនុស្ស ចេះអត់ឱនគ្នា និងមានសាមគ្គីភាព-ល-។ ចំណែកព្រះសហគមន៍កាតូលិក ក្នុងប្រទេសកម្ពុជា ក៏បានចូលរួមយ៉ាងសកម្មក្នុងការកសាងសង្គមកម្ពុជា ឱ្យមានការគោរពសិទ្ធិមនុស្ស មានយុត្តិធម៌ក្នុងសង្គម និងពង្រីកលទ្ធិប្រជាធិបតេយ្យទូទាំងប្រទេស។

**លោកបូជាចារ្យអូមែរ ហ្សឺរ៉ាល់ដូ**

CSC
**ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
**Tel/Fax : (855) 23 224 120;**
**E-mail :** csccambodia@gmail.com;
**Website :** www.catholiccambodia.org;
ក្រុមប្រឹក្សាភិបាល : លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្សឺរ៉ាល់ដូ។
ចាងហ្វាងការផ្សាយ : លោកលី សុវណ្ណា។
Licence ១៨៣ ពម.ប្រក./២៥-មិថុនា-២០០៧

**មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក** មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៨ ថ្មី ដែលជាចម្រៀងកោតសរសើរព្រះយេស៊ូគ្រីស្ត និងយុវជនផងដែរ។ តម្លៃលក់ក្នុងមួយស៊ីឌី ៨ ០០០រៀល តែប៉ុណ្ណោះ។ ហេតុដូចនេះ ប្រសិនប្រិយមិត្តមានចំណាប់អារម្មណ៍ចង់ជាវនោះ សូមទំនាក់ទំនងទូរស័ព្ទ : **០១២ ២៤៤ ៧៧៨។**

## មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក

**សេវាកម្មជាទីគាប់ចិត្ត !** ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកមានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និងMP3 និងទទួលថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មនឹងគិតក្នុងតម្លៃសមរម្យ។ សូមប្រិយមិត្តទាក់ទងទូរស័ព្ទ : **០១២ ៣៧៧ ៩៦០។**

**សារសម្រាប់មិត្តអ្នកអាន!**



បើប្រិយមិត្តចង់មានមតិយោបល់ទៅលើអត្ថបទ មានចម្ងល់ ឬចង់ជូននូវមតិរិះគន់ស្ថាបនា សូមទាក់ទងមកកាន់អាសយដ្ឋានរបស់យើងខ្ញុំ។ យើងខ្ញុំនឹងផ្តល់នូវចម្លើយដោយក្តីរីករាយ។



**សេចក្តីជូនដំណឹង !** *"ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិកដោយមិនគិតថ្លៃ"* គ្រប់អង្គការក្រុមហ៊ុន និងស្ថាប័នទាំងអស់ដែលមានបំណងចង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ ឬដំណឹងជ្រើសរើសបុគ្គលិកក្នុងតម្លៃទាបបំផុត ហើយនិងចំណេញច្រើនសូមទំនាក់ទំនងមកកាន់ការិយាល័យអ្នកនាំសារ ឬអាចទូរស័ព្ទ : ០៩២ ៧៣៧ ២៥៥។ បញ្ជាក់ : គ្រប់ដំណឹងផ្សព្វផ្សាយជ្រើសរើសបុគ្គលិកទាំងអស់ដែលគ្មាន Logo របស់អង្គការ ក្រុមហ៊ុន ឬស្ថាប័ននានា យើងខ្ញុំនឹងចុះផ្សាយដោយមិនគិតថ្លៃឡើយ។

April-2008.qxd 5/2/2008 11:29 AM Page 4

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ

## បុណ្យលើកតម្កើងព្រះជាម្ចាស់លើកព្រះយេស៊ូឡើង (ត្រូវនឹងថ្ងៃទី៤ ឧសភា ឆ្នាំ២០០៨)

(ម៉ាថាយ ២៨,១៦-២០) ព្រះសហគមន៍ធ្វើពិធីបុណ្យលើកតម្កើងព្រះជាម្ចាស់ គឺលើកព្រះយេស៊ូឡើងស្ថានបរមសុខ ៤០ថ្ងៃ នៅក្រោយព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏ពេញលេញ គឺក្រោយពីព្រះអង្គបានអប់រំក្រុមសាវ័កអំពីវត្តមានថ្មីរបស់ព្រះអង្គ។ ព្រះជាម្ចាស់បានប្រោសព្រះយេស៊ូឱ្យតើនឡើងពីចំណោមមនុស្សស្លាប់ គឺព្រះអង្គសម្តែងនូវឫទ្ធានុភាពដ៏អស្ចារ្យបំផុតក្នុងអង្គព្រះគ្រីស្ត។ ហេតុនេះហើយបានជាព្រះគ្រីស្តមានព្រះបន្ទូលទៅកាន់ក្រុមសាវ័កថា: "ខ្ញុំបានទទួលគ្រប់អំណាចទាំងនៅស្ថានបរមសុខ និងនៅលើផែនដី"។ នេះជាដំណឹងល្អដ៏សំខាន់ណាស់សម្រាប់យើងជាគ្រីស្តបរិស័ទ។ ប្រសិនបើព្រះគ្រីស្តមានអំណាចលើម្ចាស់ទឹក ម្ចាស់ដី លើខ្មោចអារក្ស អ្នកតា លើវត្ថុស័ក្តិសិទ្ធិ លើទេវតាព្រៃភ្នំ យើងមិនភ័យខ្លាចទៀតទេ។ យើងត្រូវតែពឹងផ្អែកលើព្រះយេស៊ូដែលសន្យាថា ព្រះអង្គរួមនៅជាមួយយើងជារៀងរាល់ថ្ងៃរហូតដល់ទីអវសានកាលនៃពិភពលោក។

## បុណ្យលើកតម្កើងព្រះវិញ្ញាណយាងមក (ត្រូវនឹងថ្ងៃទី១១ ឧសភា ឆ្នាំ២០០៨)

(យ៉ូហាន ២០,១៩-២៣) នៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីចាស់ ព្រះជាម្ចាស់មានព្រះបន្ទូលមកប្រជារាស្ត្រអ៊ីស្រាអែលថា: "នៅគ្រាខាងមុខ យើងនឹងចងនូវសម្ពន្ធមេត្រីថ្មីជាមួយប្រជាជនអ៊ីស្រាអែលដូចតទៅ: យើងនឹងដាក់វិន័យរបស់យើង នៅក្នុងជម្រៅចិត្តរបស់ពួកគេ យើងនឹងចារវិន័យនោះក្នុងចិត្តគំនិតរបស់ពួកគេ (យរ ៣១,៣១-៣៣)"។ នៅបុណ្យថ្ងៃទីហាសិប (ហាសិបថ្ងៃក្រោយពីបុណ្យចម្លង) ជនជាតិយូដាធ្លាប់នាំគ្នាធ្វើពិធីបុណ្យមួយ នឹករឭកអំពីព្រះជាម្ចាស់ប្រទានធម្មវិន័យនៅលើភ្នំស៊ីណៃកាលពីដើម។ នៅសម័យព្រះយេស៊ូ ជនជាតិយូដានៅតែរង់ចាំពេលព្រះជាម្ចាស់ ចងសម្ពន្ធមេត្រីថ្មីក្នុងជម្រៅចិត្តរបស់គេតាមព្រះបន្ទូលសន្យា។ តាមគម្ពីរកិច្ចការ ព្រះជាម្ចាស់ចងសម្ពន្ធមេត្រីថ្មីនេះនៅថ្ងៃបុណ្យទីហាសិប។ នៅថ្ងៃនោះ ក្រុមសាវ័កទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ជាវិញ្ញាណរបស់ព្រះយេស៊ូផ្ទាល់។ ដូច្នេះហើយយើងជាគ្រីស្តបរិស័ទមិនគ្រាន់តែជាអ្នកកាន់វិន័យឱ្យខ្ជាប់ខ្ជួនប៉ុណ្ណោះទេ តែយើងមានទំនាក់ទំនងជាប់យ៉ាងស្និទ្ធស្នាលជាមួយព្រះយេស៊ូ។ ពេលយើងទទួលព្រះកាយនិងព្រះលោហិត ពេលយើងទទួលព្រះវិញ្ញាណរបស់ព្រះគ្រីស្ត យើងទៅជាបុត្រធីតារបស់ព្រះបិតា ដូចព្រះគ្រីស្តក្នុងមនុស្សលោក។

## បុណ្យលើកតម្កើងព្រះត្រៃឯក (ត្រូវនឹងថ្ងៃទី១៨ ឧសភា ឆ្នាំ២០០៨)

(យ៉ូហាន ៣,១៦-១៨) ថ្ងៃអាទិត្យនេះជាថ្ងៃអាទិត្យទី៧ ក្នុងរដូវធម្មតា និងជាថ្ងៃដែលព្រះសហគមន៍ជ្រើសរើសដើម្បីប្រារព្ធបុណ្យលើកតម្កើងព្រះត្រៃឯក។ អត្ថបទទី២ ជាអត្ថបទចុងក្រោយបំផុតនៃលិខិតទី២ គ្រីស្តទូតប៉ូលផ្ញើជូនគ្រីស្តបរិស័ទក្រុងកូរិនថូស។ ពេលគ្រីស្តទូតប៉ូលជម្រាបសួរ ឬជម្រាបលាបងប្អូនមួយចំនួន លោកតែងជូនពរបងប្អូនក្នុងនាម ព្រះជាម្ចាស់ (ជាព្រះបិតា) ព្រះយេស៊ូគ្រីស្ត (ជាព្រះបុត្រា) និងព្រះវិញ្ញាណដ៏វិសុទ្ធ។ របៀបជម្រាបសួរ និងលាគ្នាទៅវិញទៅមកតាមរបៀបពីដើមនេះ ព្រះសហគមន៍នៅតែប្រើរហូតដល់សព្វថ្ងៃ គឺនៅពេលយើងចាប់ផ្តើមថ្វាយអភិបូជា លោកបូជាចារ្យសូត្រថា "ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ" ហើយនៅពេលលោកបូជាចារ្យសូត្រថា: "សូមឱ្យបងប្អូនបានប្រកបទៅដោយព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត បានប្រកបដោយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ជាព្រះបិតា និងសូមឱ្យបងប្អូនបានរួមរស់ជាមួយគ្នាដោយព្រះវិញ្ញាណដ៏វិសុទ្ធ" (២ ករ ១៣,១៣)។ នៅពេលគ្រីស្តបរិស័ទយើងជម្រាបសួរគ្នាដោយស្និទ្ធស្នាលរបៀបនេះ យើងបានសម្តែងថា ព្រះត្រៃឯកគង់ជាមួយយើង ហើយព្រះត្រៃឯកជាគំរូយ៉ាងអស្ចារ្យនៃសេចក្តីស្រឡាញ់របស់ព្រះសហគមន៍កាតូលិក។

## បុណ្យលើកតម្កើងព្រះកាយនិងព្រះលោហិតព្រះយេស៊ូគ្រីស្ត (ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៨)

(យ៉ូហាន ៦,៥១-៥៨) យើងជាគ្រីស្តបរិស័ទពេលថ្វាយអភិបូជា យើងទទួលព្រះកាយព្រះគ្រីស្តដែលបូជាព្រះជន្មសម្រាប់ឱ្យមនុស្សលោកមានជីវិត។ ប៉ុន្តែពេលយើងកាច់នំប៉័ង នៅពេលថ្វាយអភិបូជា យើងមិនគ្រាន់តែនឹករឭកអំពីព្រះយេស៊ូដែលបូជាព្រះជន្មប៉ុណ្ណោះទេ តែយើងសុខចិត្តបូជាជីវិតផ្ទាល់ដើម្បីឱ្យអ្នកដទៃទៀតបានទទួលជីវិតវិញ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកបូជាចារ្យ វ៉ាំងសង់ សេនេសាល់**

# សម្រាប់កុមារ


Photo: DR

**ប្អូនៗជាទីស្រឡាញ់!**

ក្នុងលេខនេះអ្នកនាំសារ សូមនាំប្អូនៗឱ្យស្គាល់ពិធីមួយទៀត គឺបុណ្យព្រះវិញ្ញាណយាងមក។

ក្រោយពេលដែលព្រះយេស៊ូបានសោយទិវង្គត និងមានព្រះជន្មថ្មីដ៏រុងរឿង ក្រុមសាវ័កមិនហ៊ានចេញក្រៅផ្ទះឡើយ ព្រោះគេខ្លាចជនជាតិយូដាធ្វើបាបដល់ពួកគេដែរ។ តាមគម្ពីរដំណឹងល្អ ព្រះយេស៊ូតែងបានបង្ហាញព្រះកាយ ឱ្យគេឃើញដើម្បីឱ្យគេជឿថា ព្រះអង្គពិតជាបានទទួលព្រះជន្មថ្មីមែន ប៉ុន្តែមិនមែនជីវិតតាមបែបរូបកាយមានសាច់មានឈាមដូចមុនទៀតទេ។ ព្រះយេស៊ូបង្ហាញគេរហូតដល់ពេលព្រះអង្គយាងឡើងស្ថានបរមសុខ។ ព្រះអង្គបានចាត់គេឱ្យទៅគ្រប់ទីកន្លែងនៅក្នុងពិភពលោក ដើម្បីប្រកាសដំណឹងអំពីលោកយេស៊ូដែលគេបានឆ្កាងសម្លាប់ ហើយព្រះជាម្ចាស់បានប្រោសឱ្យមានព្រះជន្មថ្មីដ៏រុងរឿង។

ជាដំបូងពួកសាវ័កប្រកាសដំណឹងនេះ នៅគ្រប់ទីកន្លែងក្នុងក្រុងយេរូសាឡឹម រហូតដល់ថ្ងៃទី៥០ ព្រះយេស៊ូបានសន្យាប្រទានព្រះវិញ្ញាណដល់គេ ដើម្បីឱ្យគេមានកម្លាំងចេញទៅគ្រប់ទីកន្លែងនៅក្នុងពិភពលោកទាំងមូល។

តាមគម្ពីរកិច្ចការគ្រីស្តទូត សន្តលូកាបានរៀបរាប់ថា នៅបុណ្យថ្ងៃទី៥០ ពួកសាវ័កបានជួបជុំគ្នានៅកន្លែងតែមួយ។ រំពេចនោះស្រាប់តែមានឮនូវស្នូរសន្ធឹកពីលើមេឃដូចខ្យល់បក់បោកយ៉ាងខ្លាំងពេញក្នុងផ្ទះដែលគេនៅ។ ពួកសាវ័កបានឃើញហាក់មានអណ្តាតភ្លើងបែកចេញជាពីរចុះមកសណ្ឋិតលើពួកគេម្នាក់ៗ ហើយពួកគេចាប់ផ្តើមនិយាយភាសាផ្សេងៗពីគ្នាតាមព្រះវិញ្ញាណប្រទានឱ្យ។ ក្រោយមកពួកសាវ័កបានចេញទៅគ្រប់ទីកន្លែង ដើម្បីប្រកាសដំណឹងល្អនេះ។

ព្រះសហគមន៍កាតូលិកក៏ប្រារព្ធពិធីនៃព្រឹត្តិការណ៍នេះរៀងរាល់ឆ្នាំ និងតែងធ្វើអគ្គសញ្ញាលាបថ្វាសដល់បងប្អូនដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកកាលពីបុណ្យចម្លង។ បងប្អូនទាំងនោះនឹងទទួលកម្លាំងពីព្រះវិញ្ញាណ រួចចេញទៅបំពេញបេសកកម្មរបស់ព្រះយេស៊ូដោយធ្វើជាសាក្សីអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គ គឺរស់នៅប្រកបដោយធម៌មេត្តាករុណានៃព្រះជាម្ចាស់ជាព្រះបិតានៃយើង។

**លី សុវណ្ណា**



# ព្រឹត្តិការណ៍ប្រចាំខែ

## ដើមបណ្តឹងរដ្ឋប្បវេណីសាលាក្តីខ្មែរក្រហមសម្រាប់អ្នកកំព្រា

មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមហៅកាត់ថា "CSD" បានរៀបចំសិក្ខាសាលាមួយកាលពីថ្ងៃសៅរ៍ ទី១៩ មេសា ស្តីពីការដាក់ពាក្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ក្រុមអ្នកកំព្រាឪពុកនិងម្តាយ ក្នុងរបបខ្មែរក្រហមចន្លោះពីខែមេសា ១៩៧៥ ដល់ខែមករា ១៩៧៩ ។ កញ្ញាសេង ធារី ប្រធានមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម និងជាដើមបណ្តឹងរដ្ឋប្បវេណីដែលកំពុងស្វះស្វែងដើម្បីធ្វើជាអ្នកតំណាងឱ្យក្រុមអ្នកកំព្រាក្នុងករណីព្រហ្មទណ្ឌទាក់ទងទៅនឹងមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់មាន នួន ជា ខៀវ សំផន អៀង សារី និងអ្នកស្រីអៀង ធីរិទ្ធ ។ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមនឹងពន្យល់ណែនាំក្នុងការបំពេញបែបបទនៃការបំពេញសំណុំឯកសារទាំងនេះ ។ បើតាម CSD ប្រជាពលរដ្ឋកម្ពុជាគ្រប់ខេត្ត-ក្រុង ដែលមានលក្ខណៈដូចខាងលើអាចចូលមកដាក់សំណុំបែបបទពាក្យបណ្តឹងទាំងនេះ ដោយមិនគិតថ្លៃ ។ ការដាក់ពាក្យបណ្តឹងនេះ ក៏បើកឱកាសសម្រាប់ជនរងគ្រោះខ្មែរដែលនៅឯបរទេសផងដែរ ។

## បង្សុកូលរំឭកខួបឡើងកាន់អំណាចរបស់ខ្មែរក្រហម

លោកសម រង្ស៊ី និងអ្នកចូលរួមប្រមាណជាប្រាំបីរយនាក់បានចូលរួមកាលពីថ្ងៃព្រហស្បតិ៍ទី១៧ មេសា ក្នុងពិធីបង្សុកូល និងរាប់បាត្រនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯកជាយក្រុងភ្នំពេញ ដើម្បីរំឭកដល់ខួបលើកទី៣៣ឆ្នាំ នៃកាឡើងកាន់អំណាចរបស់ពួកខ្មែរក្រហមកាលពីថ្ងៃទី១៧ មេសា ១៩៧៥ ។ នៅពីមុខលាដ៏សាកសពដែលត្រូវបានសម្លាប់ដោយឃាតកដៃដល់ខ្មែរក្រហម លោកសម រង្ស៊ី និងអ្នកចូលរួមបានស្នើសុំឱ្យសាលាក្តីខ្មែរក្រហមធ្វើការកាត់ទោសមេដឹកនាំធំៗដែលបានចាប់ខ្លួនទាំងនោះ ឱ្យបានឆាប់ ដើម្បីជួយរកយុត្តិធម៌ដល់ជនរងគ្រោះកម្ពុជាជាងមួយលានប្រាំពីរសែននាក់ ដែលត្រូវបានគេសម្លាប់ ព្រោះថាមេដឹកនាំខ្មែរក្រហមទាំងនោះ មានអាយុច្រើន ហើយចាស់ៗជិតស្លាប់អស់ហើយ ។


Photo: DR

## កម្ពុជាបដិសេធការចោទប្រកាន់របស់ថៃរឿងប្រាសាទព្រះវិហារ

នាយកដ្ឋានព័ត៌មាន និងទូរគមនាគមន៍នៃទីស្តីការគណៈរដ្ឋមន្ត្រីបានចេញផ្សាយសេចក្តីប្រកាសព័ត៌មានមួយកាលពីថ្ងៃសៅរ៍ ទី១២ មេសា ដោយធ្វើការបដិសេធទៅនឹងការចោទប្រកាន់របស់ក្រសួងការបរទេសថៃ កាលពីថ្ងៃទី១០ មេសា ថា មានការបញ្ជូនកងកម្លាំងទាហានកម្ពុជាចូលទៅក្នុងតំបន់ប្រាសាទព្រះវិហារ ដែលស្ថិតនៅព្រំដែនកម្ពុជា-ថៃ។ យោងតាមសេចក្តីប្រកាសព័ត៌មានដដែលនោះ បញ្ជាក់ថា នៅក្នុងអនុស្សារណៈនៃការយោគយល់ជំនួយស្មារតីរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលបានផ្ញើជូនឯកអគ្គរាជទូតថៃបានបញ្ជាក់យ៉ាងច្បាស់ និងយ៉ាងត្រឹមត្រូវថា គ្មានសកម្មភាពរំលោភបំពានណាមួយពីសំណាក់ភាគីកម្ពុជានោះឡើយ។ ការចោទប្រកាន់ថាមានការរំលោភបំពាន គឺជាការប្រកាន់ដោយគ្មានមូលដ្ឋាន។

**រស់ ឌីណា**

## អ.ស.ប. ប្រកាសរកជំនួយបន្ថែមក្រោយអង្ករឡើងថ្លៃ

យោងទៅតាមទីភ្នាក់ងារព័ត៌មានរ៉យទ័រកាលពីថ្ងៃទី១៦ ខែមេសា បានឱ្យដឹងថា អង្គការកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ(អ.ស.ប.) បានអំពាវនាវស្វែងរកជំនួយចំនួន ៥០០ លានដុល្លារ ដើម្បីបន្តកម្មវិធីរបស់ខ្លួន នៅក្នុងតំបន់មានវិបត្តិនានា តទៅទៀត ក្រោយពេលដែលតម្លៃអង្ករនៅលើទីផ្សារពិភពលោកបានឡើងថ្លៃហួសពីការស្មានទុក។ អ.ស.ប.បានប្រកាសថា កម្មវិធីមូលនិធិស្បៀងអាហារដំណើរការ កាលពីដើមខែមីនានៅក្នុង១តោន ចំណាយត្រឹមតែ ៤៦០ដុល្លារប៉ុណ្ណោះ ប៉ុន្តែនៅពេលនេះវាបានឡើងរហូតដល់ទៅ ៧៨០ដុល្លារ នៅក្នុងមួយតោន។

រហូតមកដល់ពេលនេះ ទីផ្សារអង្ករនៅលើពិភពលោកបានឡើងថ្លៃដល់ចំណុចកំពូលមួយ ដែលមិនដែលធ្លាប់កើតមានពីមុន ហើយវិបត្តិនៃការឡើងថ្លៃនេះ បានធ្វើឱ្យប្រទេសមួយចំនួនកើតមាននូវបញ្ហាអស្ថិរភាព។ អ្នកវិភាគបានឱ្យដឹងថា វិបត្តិនៃការឡើងថ្លៃអង្ករនេះ គឺបណ្តាលមកពីចំនួនស្តុករបស់អង្ករមានការធ្លាក់ចុះ។ តាមការរំពឹងទុកកាលពីដើមខែសីហា ពិភពលោកទាំងមូលមានអង្ករស្តុកត្រឹមតែចំនួន៧៧លានតោនប៉ុណ្ណោះ ចំនួននេះ គឺមានការធ្លាក់ចុះរហូតដល់ទៅ ៤៨ ភាគរយបើប្រៀបធៀបនឹងឆ្នាំ២០០០ ។

**ភីរម្យ**

## ពួកម៉ៅនិយមទទួលបានជោគជ័យនៅនេប៉ាល់


Photo: DR

គណបក្សកុំម្មុយនិស្តនេប៉ាល់ ដែលគេដឹងថា ជាពួកម៉ៅនិយមបានទទួលនូវជោគជ័យក្នុងការបោះឆ្នោតជាតិជាលើកទីមួយ ដើម្បីសរសេររដ្ឋធម្មនុញ្ញថ្មីមួយនៅក្នុងរាជាណាចក្រដ៏ចំណាស់មួយនៅលើពិភពលោក។

យោងតាមទីភ្នាក់ងារព័ត៌មានបារាំង ពួកម៉ៅនិយម ដែលពីមុនគេចាត់ទុកជាក្រុមឧទ្ទាមនោះបានទទួលអាសនៈ ១១៦ លើអាសនៈសរុប២៤០។ ជ័យជម្នះនេះនឹងអាចធ្វើឱ្យរបបរាជានិយមក្នុងរាជាណាចក្រដ៏ចំណាស់មួយនេះរឹតតែរង្គោះរង្គើឡើងថែមទៀត ខណៈដែលគណបក្សសមាជនេប៉ាល់ ដែលកំពុងដឹកនាំរដ្ឋាភិបាលចម្រុះទទួលបានត្រឹមតែ៣២កៅអីប៉ុណ្ណោះ។ លោកបាប៊ូរ៉ាំ បាតារ៉ៃ ជាមេដឹកនាំជាន់ខ្ពស់មួយរូបរបស់ពួកម៉ៅនិយម បានអះអាងថា ព្រះមហាក្សត្រយ៉ានិនដ្រា នឹងក្លាយទៅជាប្រជាពលរដ្ឋសាមញ្ញ។ កៅអីនៅក្នុងសភារបស់នេប៉ាល់ទាំងអស់មានចំនួន ៦០១ ក្នុងនោះកៅអីដែលទទួលបានពីការបោះឆ្នោតមាន ២៤០។ ៣៣៥កៅអីជាកៅអីតំណាងសមាមាត្រ និង ២៦កៅអីទៀត ជារបស់អតីតមន្ត្រីរដ្ឋាភិបាល។

**ភីរម្យ**

April-2008.qxd 5/2/2008 11:29 AM Page 6



# យើងមានចិត្តកាន់តែសប្បុរស និងចេះជួយអ្នកដទៃ

**ឡុង សម្ផស្ស**

កាលពីព្រឹក ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៨ កន្លងទៅនេះ នៅព្រះសហគមន៍សន្តយ៉ូសែបមានរៀបចំពិធីចែកអំណោយដល់បងប្អូនក្រីក្រ ១០០ គ្រួសារ ដែលមកពីទីកន្លែងផ្សេងៗ ក្នុងទីក្រុងភ្នំពេញដើម្បីអបអរសាទរ ក្នុងឱកាសបុណ្យព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង និងនៅក្នុងឱកាស បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនៅឆ្នាំនេះ។

ថ្លែងក្នុងឱកាសនោះលោកស៊ុយ ប៊ុនថង ជាប្រធានក្រុមប្រឹក្សារបស់ព្រះសហគមន៍ សន្តយ៉ូសែប មានប្រសាសន៍ឱ្យដឹងដែរថា: "ព្រះសហគមន៍បានខិតខំប្រមែប្រមូលនូវថវិកានិងគ្រឿងឧបភោគបរិភោគមួយចំនួន ជាអំណោយរបស់សប្បុរសជន ទាំងក្នុងនិងក្រៅប្រទេស សម្រាប់ចែកជូនដល់បងប្អូន ក្នុងឱកាសនេះ។ ទោះបីជាតិចតួចតែអាចជួយសម្រួលជីវភាពបានមួយរយៈដែរ"។ នៅពេលនោះ លោកបប់ ពិសេ បូជាចារ្យទទួលខុសត្រូវព្រះសហគមន៍សន្តយ៉ូសែប បានចាប់អារម្មណ៍ថា: "មនុស្សយើងម្នាក់ៗ គឺត្រូវការផ្លាស់ប្តូរពីមួយឆ្នាំទៅមួយឆ្នាំទៅកាន់ការអភិវឌ្ឍន៍ និងរីកចម្រើនឡើង។ ទោះបីជាក្នុងជីវិតយើង មានការខ្វះខាតខ្លះក្តី បើយើងមានចិត្តកាន់តែសប្បុរសចេះ រាប់អាន ចេះជួយ និងចេះគោរពអ្នកដទៃ យើងនឹងសប្បាយជាមួយគ្នា"។


Photo: L. Samphors

លោកយាយត្រេកអរសប្បាយនៅពេលទទួលបានអំណោយពីព្រះសហគមន៍កាតូលិក។ នេះគឺជាសក្ខីភាពបញ្ជាក់នូវសេចក្តីស្រឡាញ់ដែលមកពីជំនឿរបស់គ្រីស្តបរិស័ទ។

## សិក្ខាសាលា អំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់


Photo: S. Philong

ថ្ងៃទី១-៤ មេសា នៅទេវវិទ្យាល័យទីក្រុងភ្នំពេញមានធ្វើសិក្ខាសាលាមួយស្តីពី "ព្រះបន្ទូលរបស់ព្រះជាម្ចាស់" ដែលរៀបចំឡើងដោយលោកបូជាចារ្យប្រ៊ុយណូ កូសម៉ី អ្នកទទួលខុសត្រូវ និងដឹកនាំសិក្ខាសាលា។ សិក្ខាសាលានេះគឺមានការជំរុញលើកទឹកចិត្តដោយលោក បូជាចារ្យ Lucien Legrand អ្នកចេះដឹងជ្រៅជ្រះខាងព្រះគម្ពីរ និងជាសាស្ត្រាចារ្យដែលបង្រៀននៅក្នុងមហាវិទ្យាសន្តទេវវិទ្យាល័យទីក្រុង Bangalore នៃប្រទេសឥណ្ឌា។

លោកបូជាចារ្យ ប្រ៊ុយណូ បានមានប្រសាសន៍ថា: "ក្នុងសិក្ខាសាលា រយៈពេល ៥ថ្ងៃ មានអ្នកចូលរួមប្រមាណ ៤០នាក់។ រៀងរាល់ព្រឹក សិក្ខាកាមមានឱកាសចែករំលែកនូវ ការយល់របស់គេលើមេរៀនរបស់ Legrand។ ថ្ងៃចុងក្រោយ លោកបូជាចារ្យប្រ៊ុយណូ បានជូនវត្ថុអនុស្សាវរីយ៍ ដែលមានសញ្ញាទេវវិទ្យាល័យដល់អ្នកចូលរួមផងដែរ"។ **តន**

## ពិធីសម្ពោធដាក់ឱ្យដំណើរការរដ្ឋាករទឹកតាំងក្រសាំង


Photo: H. Sotheary

នៅថ្ងៃទី០២ មេសា រដ្ឋាករទឹកតាំងក្រសាំងបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវស្ថានីយទឹកស្អាតមួយ ជាជំនួយឥតសំណងរបស់សហភាពអឺរ៉ុបតាមរយៈអង្គការ ICS ជូនចំពោះ ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ។

នៅក្នុងពិធីសម្ពោធនោះ មានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តមណាំ ទុំ អភិបាលខេត្តកំពង់ធំ និងឯកឧត្តមភោគ សុវណ្ណរិទ្ធ រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងភ្ញៀវកិត្តិយសជាច្រើននាក់ទៀត។ ឯកឧត្តមណាំ ទុំ មានប្រសាសន៍ថា: "ទឹកមានសារៈសំខាន់ណាស់មិនអាចខ្វះបានទេសម្រាប់ជីវិតរស់នៅលើផែនដីនេះ។ ដូច្នេះនៅពេលប្រើប្រាស់ទឹក ខ្ញុំសំណូមពរដល់បងប្អូននឹកគិតទៅដល់ប្រភពទឹក និងថែទាំប្រព័ន្ធផលិតកម្មនេះដើម្បីឱ្យយើងប្រើប្រាស់បានយូរអង្វែងតទៅមុខទៀត"។ ការអនុវត្តន៍គម្រោងសាងសង់ប្រព័ន្ធទឹកស្អាតទីប្រជុំជនតាំងក្រសាំងចំណាយថវិកាអស់ប្រហែល ១៣២៤៤០០ដុល្លារ។ **ធារី**

## ការជួបជុំជាលើកដំបូង


Photo: L. Samphors

**គ្រីស្តបរិស័ទព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ប្រមាណ ៤៥០០នាក់ បានមកជួបជុំគ្នាដើម្បីចែករំលែកបទពិសោធន៍ និងផ្តល់សក្ខីភាពអំពីព្រះយេស៊ូ ទាក់ទងទៅនឹងប្រធានបទ "និទានជីវិតព្រះយេស៊ូក្នុងជីវិតផ្ទាល់ខ្លួនរបស់យើង" កាលពីថ្ងៃទី៣០ មីនា នៅសាលាបច្ចេកទេសដុនបូស្កូភ្នំពេញថ្មីក្រោមអធិបតីភាពលោកអភិបាលអេមីល ដេតម្បូ។**

**លោកបូជាចារ្យអូលីវីយេ តំណាងពេញសិទ្ធិលោកអភិបាល មានប្រសាសន៍ថា នេះជាលើកទី១ ដែលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញរៀបចំការជួបជុំដ៏ធំនេះ ដោយគ្រីស្តបរិស័ទទាំងអស់អាចចូលរួមដោយសេរី ក្នុងគោលបំណង ប្រារព្ធពិធីបិទឆ្នាំ "និទានជីវិតព្រះយេស៊ូក្នុងជីវិតផ្ទាល់ខ្លួនរបស់យើង" ដែលព្រះសហគមន៍បើកកាលពីឆ្នាំកន្លងទៅ។ ចំពោះប្រធានបទនេះ ព្រះសហគមន៍នៅភូមិភាគភ្នំពេញបានជួយគ្រីស្តបរិស័ទ តាមព្រះសហគមន៍នីមួយៗឱ្យរិះគិតពីព្រះបន្ទូលតាមខែនីមួយៗ និងធ្វើសំណាក់ធម៌រយៈពេលពេញមួយឆ្នាំផងដែរ។ វណ្ណា**





# សិក្ខាសាលា ពង្រឹងសមត្ថភាពគ្រូអប់រំជំនឿ

**សុវណ្ណា និងសម្ផស្ស**

បើតាមកម្មវិធីដែលបានគ្រោងទុក សម្រាប់ពង្រឹងសមត្ថភាព និងចំណេះដឹងឱ្យដល់អ្នកអប់រំបន្តជំនឿ សម្រាប់ព្រះសហគមន៍កាតូលិកទាំងបីភូមិភាគនៅប្រទេសកម្ពុជា មណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា បានរៀបចំនូវសិក្ខាសាលាលើកទី២ របស់ខ្លួនរយៈពេលបួនថ្ងៃពីថ្ងៃទី៥-៨ ខែមេសាកន្លងទៅ នៅឯព្រះសហគមន៍កាតូលិកចំការទៀង ខេត្តតាកែវនៅលើប្រធានបទ: "ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ និងការវិវត្តន៍នៃព្រះសហគមន៍"។

កម្មវិធីនេះមានអ្នកចូលរួមប្រមាណជាង៧០នាក់។ នៅក្នុងពេលបើកអង្គសិក្ខាសាលា លោកបូជាចារ្យអូលីវីយេ តំណាងពេញសិទ្ធិ នៃលោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ បានមានប្រសាសន៍ថា: "ការអប់រំជំនឿមានសារៈសំខាន់ណាស់ ដើម្បីជួយដល់បងប្អូនដែលកំពុងតែស្វែងយល់។ ហើយយើងម្នាក់ៗជាសាក្សីនៃជីវិតព្រះយេស៊ូ ផ្តល់នូវសក្ខីភាពព្រមទាំងចែករំលែកបទពិសោធន៍អំពីជំនឿរបស់ខ្លួនទៅដល់បងប្អូនទាំងនេះផងដែរ។ អ្នកអប់រំបន្តជំនឿដើរតួយ៉ាងសំខាន់ ក្នុងការជួយតម្រង់ផ្លូវបងប្អូនស្វែងយល់ ឱ្យស្គាល់ព្រះយេស៊ូ កាន់តែច្បាស់។ ដូច្នេះអ្នកណែនាំទាមទារនូវជំនឿ សមត្ថភាព និងចំណេះទូលំទូលាយបន្ថែមដែលទាក់ទងទៅនឹងគម្ពីរ និងព្រះសហគមន៍កាតូលិកផងដែរ"។

ចំណែកលោកបូជាចារ្យ ហ្វ្រង់ស័រ ប៉ុងសូជី ប្រធានមណ្ឌលវប្បធម៌កាតូលិកកម្ពុជា ក៏បញ្ជាក់ពីគោលបំណងនៃអង្គសិក្ខាសាលានេះថា អង្គសិក្ខាសាលានេះជួយអ្នកអប់រំជំនឿឱ្យយល់អំពីដំណើរប្រវត្តិនៃការសង្គ្រោះរបស់ព្រះជាម្ចាស់គឺតាំងពីជំនាន់លោកអាប្រាហាំ លោកម៉ូសេ រហូតដល់សម័យព្រះយេស៊ូ និងអំពីជីវិតព្រះសហគមន៍សព្វថ្ងៃ ពិសេស គឺជួយអ្នកអប់រំបន្តជំនឿឱ្យជួយអ្នកស្វែងយល់ដែលកំពុងមានវត្តមានជាមួយយើងសព្វថ្ងៃ។

លោកហ៊ិន សុភា អ្នកអប់រំបន្តជំនឿនៅព្រះសហគមន៍ចំការទៀងចាប់អារម្មណ៍ថា សិក្ខាសាលានេះបានជួយលោកឱ្យយល់កាន់តែច្បាស់ឡើងពីប្រវត្តិនៃព្រះសហគមន៍កាតូលិក ដំណើររបស់លោកប៉ូលក្នុងការប្រកាសដំណឹងល្អ និងបានស្គាល់ភូមិសាស្ត្រនៃមជ្ឈិមបូពា។ អ្នកអប់រំវ័យ ២៣ឆ្នាំ នេះ បន្តថា អង្គសិក្ខាសាលា ក៏បានជួយឱ្យជំនឿរបស់លោករីកចម្រើន និងចេះថ្លឹងថ្លែងក្នុងជីវិតផងដែរ ពិសេសទៀតនោះ លោកអាចទទួលបានគំនិតទូលំទូលាយថែមទៀត ដែលវាធ្វើឱ្យលោកងាយស្រួលក្នុងការពន្យល់គម្ពីរដល់បងប្អូនឯទៀតៗ។ ដូចគ្នានេះ ដែរ លោកលាង ហុង ជាអ្នកអប់រំមកពីព្រះសហគមន៍ខេត្តកោះកុង ភូមិភាគភ្នំពេញ ក៏បញ្ជាក់ផងដែរថា លោកបានចូលរួមក្នុងសិក្ខាសាលាអ្នកអប់រំបន្តជំនឿច្រើនដងហើយ។ ប៉ុន្តែវគ្គនេះបានជួយលោករៀនច្រើនថែមទៀតពិសេសឱ្យស្គាល់ផែនទីមជ្ឈិមបូពា ដែលជាគ្រឹះដើម្បីស្វែងយល់អំពីព្រះគម្ពីរ។

### កម្មវិធី និងកាលបរិច្ឆេទសិក្ខាសាលាបន្ទាប់

**ថ្ងៃទី១៣-១៥ ខែឧសភា: "សេចក្តីទូទៅអំពីគម្ពីរសម្ពន្ធមេត្រីចាស់"។ ទីកន្លែង: កំពង់ចាម។ ថ្ងៃទី១៤-១៥ ខែមិថុនា: "គម្ពីរសម្ពន្ធមេត្រីចាស់" បន្ត។ ទីកន្លែង: ភ្នំពេញ។ ថ្ងៃទី១៨-២០ ខែកក្កដា: "គម្ពីរសម្ពន្ធមេត្រីថ្មី"។ ទីកន្លែង: ភ្នំពេញ។ ថ្ងៃទី១១-១៤ កញ្ញា: "គម្ពីរសម្ពន្ធមេត្រីថ្មី" បន្ត។ ទីកន្លែង: ក្រុងព្រះសីហនុ។ ថ្ងៃទី១៨-១៩ តុលា: "គម្ពីរវិវរណៈ ឬ ១ ករ ១៥។ ទីកន្លែង: ភ្នំពេញ។ ថ្ងៃទី១១-១៣ វិច្ឆិកា: "វិទ្យាសាស្ត្រ និងជំនឿ កំណើតពិភពលោក។ ទីកន្លែង: ចំការទៀង តាកែវ។ ថ្ងៃទី១៣-១៤ ធ្នូ: "ប្រវត្តិសាស្ត្រព្រះសហគមន៍ទូទៅ"។ ទីកន្លែង: ភ្នំពេញ។**

**-គ្រប់ប្រជុំមានពេលអប់រំខាងអធិដ្ឋាន អំពីជីវិតខាងវិញ្ញាណ អំពីគ្រឹះនៃជំនឿ គ្រឹះនៃជីវិតគ្រីស្តបរិស័ទ អប់រំអំពីរបៀបរស់នៅក្នុងព្រះសហគមន៍ អំពីមហាសន្និបាតវ៉ាទីកង់ទី២ និងអំពីរដ្ឋពិធីបុណ្យ។**

**-បង្រៀនគរុកោសល្យដោយការអនុវត្តន៍ក្នុងសិក្ខាសាលានីមួយៗ។ -ចាត់ចែងសំណាក់ធម៌មួយឆ្នាំម្តង។**


Photo: L. Samphors

លោកបូជាចារ្យហ្វ្រង់ស័រ ប៉ុងសូជី ណែនាំអ្នកអប់រំបន្តជំនឿ

April-2008.qxd 5/2/2008 11:29 AM Page 8



# ចូលរួមលើកកម្ពស់ភាពជាសហគ្រិនសម្រាប់យុវជន

**ឡុង សម្ផស្ស**


Photo : KYCC

យុវជនអង្គុយពិភាក្សាគ្នា ជុំវិញបញ្ហាសហគ្រិនភាព

ទីផ្សារការងារសព្វថ្ងៃ មានភាពចង្អៀត ដែលជំរុញឱ្យនិស្សិតធ្វើការប្រកួតប្រជែងសមត្ថភាពការងារ ដោយគេត្រូវតែមានទាំងចំណេះដឹង គួបផ្សំនិងបទពិសោធន៍ច្រើន ទើបងាយស្រួលរកការងារធ្វើ។

លោកខន សុរិធី ជានាយកប្រតិបត្តិអង្គការយុវជនខ្មែរបោះជំរំដើម្បីវប្បធម៌ មានប្រសាសន៍ថា អង្គការយុវជនខ្មែរបោះជំរំដើម្បីវប្បធម៌ គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលបានបង្កើតឡើងតាំងខែមករា ឆ្នាំ២០០១ មកម្ល៉េះ។ អង្គការនេះបានបង្កើតឡើងក្នុងគោលបំណងចង់ក្លាយទៅជាម្ចាស់មូលនិធិឱ្យមាននិរន្តរ៍ភាពសម្រាប់កុមារ និងដើម្បីអប់រំបន្តទៅដល់យុវជន ឱ្យដុះគំនិតធ្វើជាម្ចាស់អាជីវកម្មដោយខ្លួនឯង។

សព្វថ្ងៃ អង្គការកំពុងធ្វើសកម្មភាពទៅលើគម្រោងការនៃសិទ្ធិកុមារយេនឌ័រ និងភាពជាសហគ្រិនផងដែរ។ទាក់ទងទៅនឹងគម្រោងសហគ្រិននេះ លោកសុរិធី ក៏បានបន្ថែមទៀតថា ដោយសារមើលឃើញបញ្ហាមួយគឺថា ទន្ទឹមនិងទីផ្សារការងារមិនសូវមានច្រើន និងចង្អៀត ចំណែកនិស្សិតម្នាក់ៗ ដែលទើបបញ្ចប់ការសិក្សាពីសកលវិទ្យាល័យ គិតតែពីខិតខំស្វែងរកការងារធ្វើដោយមិនចាប់អារម្មណ៍ទៅលើភាពជាអ្នកដឹកនាំលើជីវិតខ្លួនឯងទេ។ ឆ្លងតាមបទពិសោធន៍នៃបញ្ហាទាំងនេះ ទើបអង្គការរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលភាពជាសហគ្រិនឱ្យយុវជន ដើម្បីជួយបំផុសគំនិតយុវជន ឱ្យមានការតាំងចិត្ត ហើយនិងជឿជាក់ទៅលើសមត្ថភាពខ្លួនឯង ពោលគឺហ៊ានគិត ហ៊ានសម្រេច និងហ៊ានធ្វើ។

សូមបញ្ជាក់ដែរថាក្រោយបញ្ចប់វគ្គសិក្សា អង្គការនឹងផ្តល់ប្រឹក្សាយោបល់ ដល់និស្សិតម្នាក់ៗ រួចជួយរៀបចំចងក្រងបង្កើតនូវសម្ពន្ធសហគ្រិន ដោយក្នុងមួយក្រុមៗ មានសមាជិកពី៥ ទៅ៦នាក់ ដើម្បីធ្វើការពិភាក្សាគ្នា បង្កើតជាគំនិត បើកធ្វើអាជីវកម្មអ្វីមួយ។ ជាក់ស្តែងអតីតសិក្ខាកាមមួយចំនួនបានរួមគ្នាបើកអាជីវកម្មដូចជា ក្រុមហ៊ុនផលិតទឹកបរិសុទ្ធ ហាងកាត់ដេរ ក្រុមហ៊ុនផលិត ស៊ីឌី"ស្បែតអប់រំ" ឬហាងកុំម្ព្យូទ័របាយកញ្ចប់ជាដើម។

អង្គការយុវជនខ្មែរបោះជំរំ ដើម្បីវប្បធម៌ គឺមានទីតាំងនៅផ្ទះលេខ ២៣៦ ផ្លូវលេខ ៣៧៦ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ឬទូរស័ព្ទទំនាក់ទំនង: ០១២ ៧៣៦ ១៦៦។

## ជុំ សារឿន: "បង្កើតអាជីវកម្ម ដោយហ៊ានប្រើគំនិតខ្លួនឯង"

លោកជុំ សារឿន អាយុ៣០ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពត។ សព្វថ្ងៃលោករស់នៅសង្កាត់ ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

លោកក៏ជាអតីតសិក្ខាកាមមួយរូប ដែលធ្លាប់បានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលស្តីអំពីគម្រោងការសហគ្រិន សម្រាប់យុវជនរបស់អង្គការយុវជនខ្មែរបោះជំរំដើម្បីវប្បធម៌ផងដែរ។

ហេតុដូច្នេះ លោកបានចែករំលែកនូវបទពិសោធន៍ដែលលោកបានជួបប្រទះថាបន្ទាប់ពីលោកបានឆ្លងកាត់វគ្គបណ្តុះបណ្តាល ស្តីពីគម្រោងសហគ្រិននេះមក វាបានជួយលោកឱ្យមានជំហរ និងក្លាយទៅជាមនុស្សម្នាក់ដែលមានលក្ខណៈជាអ្នកដឹកនាំ ចង់ធ្វើអ្វីមួយតាមសមត្ថភាពរបស់ខ្លួន ដោយឈរនៅលើជំហរនិងឆន្ទៈរបស់ខ្លួនឯង។ វគ្គបណ្តុះបណ្តាលបានជួយលោកឱ្យមានកម្លាំងចិត្ត និងមានភាពក្លាហានជាងមុន ពោលគឺថា លោកហ៊ានធ្វើការសម្រេចចិត្ត


Photo : L. samphors

ទៅលើកិច្ចការធំៗបាន ដែលកាលពីពេលមុននោះលោក មិនសូវមានភាពក្លាហានក្នុងការគិត ឬហ៊ានសម្រេចចិត្ត ឬចាប់ផ្តើមធ្វើការងារអ្វីឡើយ សូម្បីតែបន្តិចក៏គ្មានដែរ។

លោកសារឿន បញ្ជាក់បន្ថែមទៀតថា: "ក្រោយពីទទួលចំណេះដឹងពីវគ្គសិក្សានោះមក ខ្ញុំមានគំនិតមួយ គឺខ្ញុំបើកជាអាជីវកម្មខ្នាតតូចមួយ ដោយប្រើគំនិត និងដើមទុនបន្តិចបន្តួចខ្លួនឯងរួមជាមួយមិត្តភក្តិ បង្កើតបានហាងកាត់ដេរមួយ ដែលដាក់ឈ្មោះថាហាងកាត់ដេរ "ដាសី" ដែលស្ថិតនៅសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ហាងកាត់ដេរនេះ គឺមានទទួលបម្រើសេវាកម្ម កាត់ដេរសម្លៀកបំពាក់បុរសនារីគ្រប់ម៉ូតសម័យនិយម។







Photo : L. Samphors

# យុវជនគួរប្រើប្រាស់ អ៊ីនធឺណេតបែបណា?

**ជាត សំភី**

ជាមួយការរីកចម្រើននៃបច្ចេកវិជ្ជាថ្មីៗ អ៊ីនធឺណេតបានក្លាយទៅជាប្រព័ន្ធមួយយ៉ាងសំខាន់ ក្នុងវិស័យទូរគមនាគមន៍។ មនុស្សម្នាចូលចិត្តប្រើប្រាស់អ៊ីនធឺណេត ទុកជាមធ្យោបាយ ដើម្បីពង្រីកចំណេះដឹង កំសាន្ត និងធ្វើការប្រាស្រ័យទាក់ទងគ្នា ពីព្រោះវាមានផ្ទុកនូវទិន្នន័យដ៏ទូលំទូលាយ និងអាចទាក់ទងគ្នាបានជុំវិញពិភពលោកទៀតផង។

លោកទូច សិរីសិទ្ធី ប្រធានដេប៉ាតឺម៉ង់វិទ្យាសាស្ត្រកុំព្យូទ័រនៅវិទ្យាស្ថានបច្ចេកវិជ្ជាកម្ពុជា ក៏បានមានប្រសាសន៍ថា: "អ៊ីនធឺណេត ប្រៀបបាននឹងឃ្លាំងបណ្ណាល័យមួយដែលផ្ទុកនូវទិន្នន័យរាប់មិនអស់ គឺបើយើងឆ្ងល់ពីអ្វី គឺយើងអាចស្វែងរកបាន"។

ជាការពិតណាស់ គេអាចប្រើប្រាស់អ៊ីនធឺណេត ធ្វើការសិក្សាស្រាវជ្រាវពីចំណេះដឹងផ្សេងៗ អាចរៀនជាមួយនិងគ្រូនៅបរទេស ផ្ញើអ៊ីមែល លេងល្បែងកំសាន្ត មើលរូប និងស្តាប់ចម្រៀង-ល-។ លើសពីនេះ គេក៏អាចផ្សព្វផ្សាយចំណេះដឹង ដែលខ្លួនមានទៅកាន់អ្នកដទៃបានដែរតាមរយៈបង្កើតវិបសាយផ្ទាល់ខ្លួន។ តែដោយសារអ៊ីនធឺណេតជាឃ្លាំងព័ត៌មាន វាក៏ផ្ទុកនៅអ្វីដែលមិនល្អផងដែរ។

លោកទូច សិរីសិទ្ធី បន្ថែមថា: "បើយើងបើកមើលអ្វីដែលពុំល្អ គេហៅថាការប្រើខុសលើអ៊ីនធឺណេត ដូច្នេះទាល់តែអ្នកប្រើប្រាស់ ចេះថ្លឹងថ្លែងមើលនូវអ្វីដែលល្អ និងអ្វីដែលមិនល្អ ឬអ្វីដែលពិត និងមិនពិតដើម្បីជាប្រយោជន៍សម្រាប់ខ្លួនឯង"។

មកដល់ត្រង់ចំនុចនេះដែរ លោកម៉ន ពេជ្រខេមរា សាស្ត្រាចារ្យព័ត៌មានវិទ្យានៅសកលវិទ្យាល័យពុទ្ធិសាស្ត្រ ទីក្រុងភ្នំពេញ មានទស្សនៈថា: "ខ្ញុំសង្កេតឃើញថា យុវជនប្រើប្រាស់អ៊ីនធឺណេតសម្រាប់ជាផលប្រយោជន៍ច្រើនបែបយ៉ាងណាស់។អ្នកខ្លះប្រើប្រាស់ដើម្បីទំនាក់ទំនងគ្នា សិក្សាស្រាវជ្រាវ និងបង្កើនចំណេះដឹងបន្ថែម។ តែអ្នកខ្លះវិញប្រើប្រាស់ដើម្បីតែលេងល្បែងកំសាន្ត បើកមើលអ្វីដែលមិនសមរម្យ អាសអាភាស ដែលនាំឱ្យខុសក្រមសីលធម៌និងប្រពៃណីខ្មែរ។ ខ្ញុំមិនលើកទឹកចិត្តឱ្យពួកគេធ្វើដូច្នេះឡើយ។ ចំពោះខ្ញុំ យុវជនខ្មែរគួរតែស្រាវជ្រាវពីអ៊ីនធឺណេត តាមមុខជំនាញដែលយើងរៀន ដូចជាបើយើងរៀនពីព័ត៌មានវិទ្យា យើងគួរមើលមេរៀនព័ត៌មានវិទ្យា ឬបើយើងរៀនពីពាណិជ្ជកម្ម យើងមើលមេរៀនពាណិជ្ជកម្ម។ ជាងនេះ យុវជនគួរមើលព័ត៌មានអំពីប្រទេសជាតិខ្លួនឯងតាមរយៈវិបសាយខ្មែរថ្មីៗ និងតាមដានព័ត៌មានអំពីប្រទេសផ្សេងៗផងដែរដើម្បីទុកជាចំណេះដឹង"។

ដូច្នេះតើយុវជនគួរប្រើប្រាស់អ៊ីនធឺណេត យ៉ាងដូចម្តេច? ដើម្បីជាផលប្រយោជន៍សម្រាប់ខ្លួនឯង នាពេលបច្ចុប្បន្ន និងទៅអនាគតយូរអង្វែងទៅមុខ។ ទាំងនេះគឺអាស្រ័យលើភាពវាងវៃរបស់ម្នាក់ៗ។

យុវជនផាន ម៉ៅ អាយុ ២៥ឆ្នាំ និស្សិតវិទ្យាសាស្ត្រកុំព្យូទ័រ ឆ្នាំទី៤ នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ និយាយថា អ៊ីនធឺណេតផ្តល់អត្ថប្រយោជន៍ជាច្រើនណាស់ មានទាំងការសិក្សាជ្រាវស្រាវ និងការលេងកំសាន្ត។ ប៉ុន្តែសំខាន់ យើងត្រូវចេះបែងចែកពេលវេលាក្នុងការប្រើវា។ បើមិនដូច្នោះទេ វានឹងធ្វើឱ្យយើងបាត់បង់នូវពេលវេលាដ៏មានតម្លៃ។យ៉ាងណាមិញយុវនារីរស់ សិរីសោភា មានការយល់ឃើញថា អត្ថប្រយោជន៍សំខាន់គឺថា យើងអាចស្វែងរកព័ត៌មានបានជុំវិញពិភពលោក និងទំនាក់ទំនងគ្នា បានគ្រប់ទីកន្លែង។ និស្សិតកុំព្យូទ័រឆ្នាំទី៤ នៅឯសកលវិទ្យាល័យពុទ្ធិសាស្ត្ររូបនេះ និយាយថា: "ខ្ញុំក៏ប្រើប្រាស់អ៊ីនធឺណេត ដើម្បីជ្រាវស្រាវឯកសារផ្សេងៗ យកមកធ្វើកិច្ចការសាលា ដែលធ្វើឱ្យការសិក្សាខ្ញុំបានចម្រើនជាងមុន"។ ចំណែកឯយុវជនអ៊ិន វណ្ណៈ អាយុ២៥ឆ្នាំជានិស្សិតឆ្នាំទី៤ ខាងផ្នែកកុំព្យូទ័រនេះដែរ និយាយសង្កត់ធ្ងន់ថា: "ខ្ញុំមិនចូលចិត្តជជែកគ្នាលេងតាមអ៊ីនធឺណេតស្វែងរកមិត្តទេ ពីព្រោះមានការបោកប្រាស់គ្នា និងម្យ៉ាងទៀត បើយើងកំសាន្តច្រើនពេក ឬបើមើលរូបភាពអាសអាភាស វាធ្វើឱ្យខាតពេល និងប៉ះពាល់ដល់ការសិក្សាផង"។

April-2008.qxd 5/2/2008 11:29 AM Page 10

## បទយកការណ៍

# ខ្មែរមកពីបរទេស និងការអភិវឌ្ឍន៍ប្រទេសកម្ពុជា

លោករស់ ឌីណា

ការរួមគ្នាជួយកសាងប្រទេស ក្រោយសុខសន្តិភាព ដោយមានការចូលរួមពីជនជាតិខ្មែរ មកពីបរទេស អ្នកខ្លះបានចូលរួមផ្នែកនយោបាយ ការអប់រំបណ្តុះបណ្តាលធនធានមនុស្ស ការអភិវឌ្ឍន៍សង្គម និងជំនួញនានា។ ជុំវិញការចូលរួមស្ថាបនាសង្គមនេះ ម្នាក់ៗមានជំនាញ និងទស្សនៈផ្សេងពីគ្នា។

ក្រោយពេលភ្លើងសង្គ្រាមស៊ីវិលនៅក្នុងស្រុក ជាងសាមសិបឆ្នាំ ត្រូវរលត់បន្តិចម្តងៗ និងបន្ទាប់ពីមានកិច្ច ព្រមព្រៀងរវាងភាគីខ្មែរក្នុងជម្លោះ នាទីក្រុងប៉ារីស នៅប្រទេសបារាំងឆ្នាំ១៩៩១ ប្រជាជនខ្មែរមួយចំនួនដែលបានភៀសខ្លួនដោយសារសង្គ្រាមទៅបរទេស បានវិលត្រឡប់ចូលប្រទេសវិញ បន្តិចម្តងៗ គឺដើម្បីចូលរួមស្តារ និងកសាងប្រទេសជាតិឡើងវិញរួមជាមួយនឹងចំណេះវិជ្ជាដែលខ្លួនមាន។ ក្នុងចំណោមអ្នកទាំងនោះ អ្នកខ្លះក៏បានចូលរួមក្នុងវិស័យនយោបាយ សង្គម ជំនួញ និងអង្គការក្រៅរដ្ឋាភិបាលនានានៅក្នុងប្រទេសកម្ពុជា។

**ការចូលរួមរបស់អ្នកនយោបាយ**

លោកសុន ឆ័យ ជាតំណាងរាស្ត្រគណបក្សសមរង្ស៊ី ដែលបានរត់គេចខ្លួនទៅរស់នៅប្រទេសអូស្ត្រាលី កាលពីឆ្នាំ១៩៧៩ ក៏បានមានប្រសាសន៍ថា លោកបានវិលចូលប្រទេសកម្ពុជាវិញ កាលពីឆ្នាំ១៩៩១ នៅក្រោមកម្មវិធីជំនួយប្រទេសអូស្ត្រាលីលើផ្នែកអប់រំ។ លោកសុន ឆ័យ បានចូលរួមបណ្តុះបណ្តាលគរុកោសល្យ ផ្នែកភាសាអង់គ្លេសខេត្ត-ក្រុង រយៈពេល២ឆ្នាំ។ លោកបានអះអាងថា: "ខ្ញុំចង់មកជួយស្រុករបស់ខ្ញុំជាមួយនិងចំណេះវិជ្ជាដែលខ្ញុំបានរៀនសូត្រខ្លះពីគេមកដើម្បីរៀបចំស្រុកទេសរបស់ខ្ញុំ"។ ក្រោយមក អតីតសាស្ត្រាចារ្យរូបនេះ ក៏បានលោតចូលទៅប្រឡូក នៅក្នុងឆាកនយោបាយ កាលពីឆ្នាំ ១៩៩៣ ហើយត្រូវបានជាប់ឆ្នោតជាតំណាងរាស្ត្រចំនួនបីអាណត្តិ ជាបន្តបន្ទាប់នៅក្នុងក្រុងភ្នំពេញ។ តំណាងរាស្ត្ររូបនេះបានពោលបញ្ជាក់ថា : "ក្នុងតួនាទីជាតំណាងរាស្ត្រ យើងបានជំរុញឱ្យមាននូវការផ្លាស់ប្តូរពីរបបរដ្ឋកម្ពុជា ដែលមានគណបក្ស តែមួយ ហើយពីសភាដែលគ្មានយោបល់ និងធ្វើតាមរដ្ឋាភិបាលឱ្យមកជាយល់ដឹងអំពីតួនាទីថ្មី និងជំរុញដល់ការធ្វើច្បាប់"។



Photo : R. Dina

### ចរន្តនៃការភៀសខ្លួនរបស់ ប្រជាជនកម្ពុជាទៅបរទេស

**តាមការសន្និដ្ឋាន រលកនៃជនភៀសខ្លួនខ្មែរទៅរស់នៅឯបរទេសកើតមានក្រោយពីរដ្ឋប្រហារឆ្នាំ១៩៧០។ ពេលនោះមន្ត្រីមានអំណាច និងអ្នកមានមួយចំនួនបានបញ្ជូនកូន និងប្រពន្ធរបស់ខ្លួនឱ្យទៅបន្តការសិក្សា និងស្នាក់នៅបរទេស។ ឆ្នាំ១៩៧៥ ប្រជាជនកម្ពុជាមួយចំនួនធំបានភៀសខ្លួនទៅនៅប្រទេសបារាំង។ ដោយឡែក អតីតយោធារបបសាធារណរដ្ឋ បានជ្រើសរើសយកសហរដ្ឋអាមេរិក។ ឆ្នាំ១៩៨០- ១៩៩១ ចរន្តនៃជនភៀសខ្លួននៅតែបន្តរត់ចូលទៅរស់នៅក្នុងជំរំឯដីថៃ ដើម្បីបានសិទ្ធិជ្រកកោណនៅឯបរទេស។ ឆ្នាំ ១៩៩១-១៩៩៣ ការរត់គេចដោយសង្គ្រាមស្ទើរតែបញ្ចប់។ ក្រោយឆ្នាំ១៩៩៣ មានចរន្តជនភៀសខ្លួនបែបនយោបាយ ឬក្រោមរូបភាពបន្តការសិក្សានៅបរទេស ហើយមិនត្រលប់មកវិញឡើយ។**

**បញ្ញវន្ត និងការអភិវឌ្ឍន៍**

ដោយឡែកលោកបណ្ឌិតរស់ ចន្ទ្រាបុត្រ ជាជនខ្មែរមកពីប្រទេសបារាំង បច្ចុប្បន្ន លោកជាអនុប្រធានរាជបណ្ឌិតសភាកម្ពុជា។ លោកមិនជ្រើសរើសជាអ្នកនយោបាយទេ។ ជាមួយនិងចំណេះវិជ្ជានិងបទពិសោធន៍ដែលមាន លោកក៏បានចាប់អារម្មណ៍ទៅលើផ្នែកអភិវឌ្ឍន៍ធនធានមនុស្ស។ លោកបណ្ឌិតក៏បានពោលបញ្ជាក់ថា : "អ្នកចូលរួមទាំងអស់នៅរាជបណ្ឌិតសភាគិតតែពីការបណ្តុះបណ្តាល ព្រោះយើងឃើញថា ខ្មែរខ្វះអ្នកស្រាវជ្រាវ និងធនធានមនុស្ស។ យើងគ្មានមហិច្ឆតាធ្វើនយោបាយ ជារដ្ឋមន្ត្រី ឬតំណាងរាស្ត្រទេ។ នយោបាយទុកឱ្យគេធ្វើចុះ។ យើងចង់ធ្វើអ្នកបច្ចេកទេសចងក្រងប្រវត្តិ-សាស្ត្រ និងបណ្តុះបណ្តាលនូវព្រលឹងជាតិ។ លោកបណ្ឌិតបានបញ្ជាក់ថា ចាប់ពីឆ្នាំ២០០០មក រាជបណ្ឌិតសភាកម្ពុជា បានបណ្តុះបណ្តាលនូវថ្នាក់បរិ-ញ្ញាបត្រជាន់ខ្ពស់ចំនួន ២០០នាក់ ក្នុងនោះ និស្សិតមានចំនួន៥០នាក់ បានបញ្ចប់ថ្នាក់បណ្ឌិត។ លោកសាស្ត្រាចារ្យបានចាត់ទុកធនធានមនុស្សទាំងនេះជាផ្នែកមួយនៃធនាគារខួរក្បាលរបស់ប្រទេសកម្ពុជា និងដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ។

**សង្គមស៊ីវិល និងការបណ្តុះបណ្តាល**

លោកសំផុន កានដារ៉ា ជាយុវជនខ្មែរសញ្ជាតិបារាំង អាយុ៣៣ឆ្នាំ មានគំនិតដូចលោកបណ្ឌិតរស់ ចន្ទ្រាបុត្រដែរក្នុងការកសាងនូវធនធានមនុស្សនៅស្រុកខ្មែរ។ កានដារ៉ា ជាវិស្វករផ្នែកព័ត៌មានវិទ្យា ហើយសព្វថ្ងៃនេះ លោកគឺជានាយកចាត់ការទូទៅរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលព័ត៌មានវិទ្យា CIST។ វិស្វកររូបនេះ បានមករស់នៅស្រុកខ្មែរ កាលពីឆ្នាំ ២០០៥ ជាមួយនឹងគម្រោងរបស់អង្គការ CIST ដែលអង្គការនេះ បានផ្តល់ការបណ្តុះបណ្តាលដោយឥតគិតថ្លៃដល់យុវជនខ្មែរក្រីក្រ នៅតាមស្រុកស្រែចំការឆ្ងាយៗ ដែលគ្មានលទ្ធភាព។ លោកកានដារ៉ា បានរៀបរាប់ថា : "យើងបានចុះទៅស្វែងរកយុវ-ជនក្រីក្រនៅតាមទីជនបទ ដែលគេមានសមត្ថភាពសិក្សា និងយកមកបណ្តុះបណ្តាលសម្រាប់ក្នុងរយៈពេល២ឆ្នាំ ដើម្បីឱ្យគេក្លាយទៅជាអ្នកបច្ចេកទេសព័ត៌មានវិទ្យា"។ យោងតាមប្រសាសន៍របស់លោកនាយកចាត់ការទូទៅរូបនេះ និស្សិតទាំងអស់នេះគឺជ្រើសរើស មកពីខេត្ត បន្ទាយមានជ័យ សៀមរាប បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង មណ្ឌលគិរី ហើយនិងតាកែវ។ ក្នុងមួយឆ្នាំៗ CIST បានទទួលសិស្សឱ្យចូលរៀនចំនួន ២៥០នាក់។ ជាមួយការងារទាំងនេះ លោកកានដារ៉ាបានបញ្ជាក់ថា: "យកចំណេះមកជួយស្រុកទេស គឺខ្ញុំសប្បាយចិត្តនឹងធ្វើការងារណាស់។ ការងារអស់ទាំងនេះ វាមានអត្ថន័យ និងមានប្រយោជន៍ច្រើនសម្រាប់កម្ពុជា។ តែខ្លួនខ្ញុំមិនអាចផ្លាស់ប្តូរអ្វីទាំងអស់នោះទេ គឺគ្រាន់តែរៀបចំផ្លូវឱ្យយុវជនដើរតែប៉ុណ្ណោះ"។

**មកពីបរទេសសុំរស់ជិតកសិករ**

ផ្ទុយពីគេឯង ជាអតីតកម្មករក្នុងរោងចក្ររថយន្តស៊ីត្រូអ៊ែននៅប្រទេសបារាំង លោកផាន ហ៊ាំ អាយុ ៦៥ឆ្នាំ បានវិលរកទ្រនុំចាស់ និងរស់នៅក្នុងនាមជាកូនឈ្នួញលក់ជីសម្រាប់ដាក់ស្រែដល់កសិករដើម្បីចិញ្ចឹមជីវភាព។សព្វថ្ងៃនេះលោកបានរស់នៅយ៉ាងស្ងៀមស្ងាត់តាំងពីឆ្នាំ១៩៩៧មក ក្នុងភូមិក្បាលដំរី ស្រុកគិរីវង្ស ខេត្តតាកែវ។ ក្រៅពីរបរចិញ្ចឹមជីវិតផាន ហ៊ាំ បានចូលរួមកសាងវត្តក្នុងភូមិរបស់លោកជាមួយចាស់ៗជិតខាង នៅក្នុងនាមលោកជាគណៈកម្មាធិការវត្តសុបិន្តណារាម។

**ការយល់ឃើញផ្ទុយគ្នាក្នុងសង្គមកម្ពុជាបច្ចុប្បន្ន**

ទន្ទឹមនឹងការពួតដៃគ្នា ចូលរួមកសាងប្រទេសជាតិឡើងវិញ ពីសំណាក់អាណិកជនខ្មែរ មកពីបរទេស អ្នកខ្លះក៏នៅមិនទាន់សម្របខ្លួនបានទាំងស្រុងទៅនឹងស្ថានភាពរស់នៅបច្ចុប្បន្នទេ។ លោកកានដារ៉ា បានលើកឡើងថា លោកគឺហាក់ដូចជានៅមានការលំបាក នៅពេលដែលលោកមានបញ្ហាសុខភាព គឺខុសពីនៅប្រទេសបារាំង ដែលលោកទទួលបាននូវសេវានេះយ៉ាងយកចិត្តទុកដាក់ ហើយមិនចំណាយប្រាក់ទេ។ លោកផាន ហ៊ាំ ដែលបានលាក់ខ្លួននៅឯស្រុកស្រែចំការរិះគន់ថា ស្រុកខ្មែរបច្ចុប្បន្ន នៅមិនទាន់មានការអនុវត្តន៏ច្បាប់បានត្រឹមត្រូវនៅឡើយទេ។ លោកក៏បានចោទប្រកាន់ទៀតថា មានអ្នកធំមួយចំនួនប្រើអំណាចផ្តាច់ការ និងពុករលួយ។

លោកសុនឆ័យ បានកត់សម្គាល់ថា ក្រោយពីព្រឹត្តិ-ការណ៍ថ្ងៃទី៥-៦ កក្កដា ស្ថានភាពក្នុងសភាក៏មានការប្រែប្រួល។ លោកបានគូសបញ្ជាក់ថា: "ស្ថាន-ភាពភ័យខ្លាចត្រូវបានបង្កើតឡើងវិញ ហើយយើងឃើញថា មាននូវរបៀបគ្រប់គ្រងមួយតាមរបៀបគណបក្សអំណាចផ្តាច់ការ។ ពិសេសរដ្ឋសភាកាន់តែដុនដាប់ទៅៗ ក្រោយពេលទ្រង់រណឫទ្ធិបានលាលែងពីប្រធានសភា។ តាំងពីពេលនោះមក គណ-បក្សកាន់អំណាចជំរុញការគ្រប់គ្រងប្រទេស តាមបែបឆ្នាំ១៩៨០"។ ទោះជាយ៉ាងនេះ តំណាងរាស្ត្ររូបនេះ បានកោតសរសើរដល់ទឹកចិត្តក្លាហានរបស់ប្រជារាស្ត្របច្ចុប្បន្ននេះថា មានសេចក្តីអង់អាចនិងយល់ដឹងច្រើនឡើងៗ ផ្ទុយពីឆ្នាំ១៩៨០។

ផ្ទុយទៅវិញក្នុងនាមជាបញ្ញវន្ត និងជាអ្នកឯកទេសដែលមិនពាក់ព័ន្ធនឹងនយោបាយលោកបណ្ឌិត រស់ចន្ទ្រាបុត្រ បានពោលបញ្ជាក់ថា ក្រុមបញ្ញវន្តដូចជាលោកបានទទួលការយកចិត្តទុកដាក់ និងឱ្យតម្លៃពីរាជរដ្ឋាភិបាល។ លោកនឹងខិតខំព្យាយាមធ្វើយ៉ាងណាដើម្បីបញ្ចេញសមត្ថភាពចំណេះដឹង និងគំនិតស្មោះត្រង់របស់លោកដើម្បីបញ្ជាក់ថា លោកពុំចង់បានអ្វី ក្រៅតែពីជួយសហការ ជួយរួបរួមអភិវឌ្ឍប្រទេសជាតិទេ ហើយលោកបណ្ឌិតសង្ឃឹមថា ថ្ងៃក្រោយ នឹងមានខ្មែរដែលមានចំណេះដឹងខ្ពង់ខ្ពស់មួយចំនួនទៀត ដែលពេលបច្ចុប្បន្នរស់នៅបរទេសនឹងវិលត្រឡប់មកវិញដើម្បីចូលរួមជួយកសាងនិងអភិវឌ្ឍប្រទេសជាតិឱ្យបានរុងរឿង។

### ចរន្តនៃការវិលចូលស្រុកវិញរបស់ជនជាតិខ្មែរ

**ការវិលចូលប្រទេសវិញរបស់ជនកម្ពុជា ដែលរស់នៅបរទេស មានការវាយតម្លៃផ្សេងៗពីគ្នា។ លោកបណ្ឌិតរស់ ចន្ទ្រាបុត្រ បានធ្វើការសន្និដ្ឋានដោយបែងចែកជាបីក្រុម។ ទី១ ក្រុមអ្នកតស៊ូនយោបាយ : អាចមាននៅចន្លោះឆ្នាំ១៩៧៩ ដល់១៩៩១។ មួយចំនួននៃអ្នកទាំងនោះ បានចូលរួមក្នុងចលនា "រំដោះជាតិ" នៅតាមព្រំដែន។ នៅក្រោយកិច្ចព្រមព្រៀងក្រុងប៉ារីស ១៩៩១ ពួកគេបានចូលមកស្រុកវិញដោយមួយចំនួនធំមានតួនាទីសំខាន់ៗ ក្នុងរដ្ឋាភិ-បាល។ ទី២ ក្រុមអ្នកនយោបាយ និងអ្នកធ្វើការNGO : ឆ្នាំ១៩៩១-១៩៩៧ មានអ្នកត្រលប់មកធ្វើនយោបាយច្រើនជាមួយហ្វ៊ុនស៊ិនប៉ិច។ ឆ្នាំ១៩៩៧ : មានជនជាតិខ្មែរមកពីបរទេសតិចតួចមកធ្វើការតាមរយៈអង្គការក្រៅរដ្ឋាភិបាល។ ផ្ទុយទៅវិញមួយចំនួនធំនៃពួកគេចូលមកតាមរយៈគណបក្សប្រជាជន។ ទី៣ ក្រុមបញ្ញវន្ត និងអ្នករកស៊ី : ឆ្នាំ១៩៩៧ -២០០០ ភាគច្រើននៃអ្នកត្រលប់ចូលស្រុកវិញជាបញ្ញវន្ត។ ឆ្នាំ២០០៣ : អ្នកជំនួញ អ្នកដែលមករស់ជាមួយគ្រួសារ និងអ្នកចូលនិវត្តន៍។**

## កសិកម្ម

# វិធីសាស្ត្រនៃការចិញ្ចឹមទាឱ្យបានល្អ

**ជាត សំភី**



Photos: L. Samphors

តាមប្រសាសន៍លោកគីម ម៉េងសែ ជាអ្នកឯកទេសចិញ្ចឹមទានៅអង្គការសេដាក បានឱ្យដឹងថា ប្រជាកសិករត្រូវដឹងអំពីគោលបំណងខ្លួន ក្នុងការចិញ្ចឹមទា ពីព្រោះពូជទាមានច្រើនប្រភេទ ដូចជាពូជយកសាច់ ចិញ្ចឹមយកស៊ុត និងសាច់ ឬចិញ្ចឹមយកសាច់សុទ្ធ។ បន្ទាប់មកគឺគាត់ជ្រើសរើសពូជឱ្យត្រូវតាមនោះ។ កសិករត្រូវទិញពូជពីកន្លែងដែលផលិតពូជលក់ និងជាកន្លែងមិនមានជំងឺរាតត្បាត។

នៅពេលយកកូនទាមកចិញ្ចឹមដំបូង កសិករត្រូវធ្វើយ៉ាងណា ពេលយប់ ដាក់ឱ្យពួកវាទទួលកម្តៅបានគ្រប់គ្រាន់ដូចជាយកបាវ ឬក្រណាត់មកហ៊ុមទ្រុងវាជាដើម ពីព្រោះបើរងា ពួកវាដេកគលើគ្នាងាប់។ ហើយគួរឱ្យវាស៊ីខ្ទឹមស ឬខ្ញីដើម្បីឱ្យខ្លួនវាទទួលនូវកម្តៅ និងការពារជំងឺ។ កសិករ ត្រូវតាមដានបោចរោមលើគូទកូនទា កុំឱ្យវាជាប់លាមកព្រោះវាអាចធ្វើឱ្យកូនទារលាកស្លាប់តែម្តង។

សម្រាប់ការចិញ្ចឹមទាជាលក្ខណៈគ្រួសារ ពី១០ទៅ២០ក្បាល កសិករដែលចិញ្ចឹមទាយកពង ត្រូវរៀបចំធ្លាមួយដែលមានស្រះទឹកតូច និងដីគោកសម្រាប់ឱ្យទាលេង។ ធ្លាត្រូវព័ទ្ធរបងកម្ពស់កន្លះម៉ែត្រកុំឱ្យទាលោតចេញ។ កសិករត្រូវរៀបចំទ្រុងដេក ដែលមានទំហំមួយម៉ែត្រ គុណពីរម៉ែត្រ និងធ្វើសំបុកឱ្យបានត្រឹមត្រូវ។ ប៉ុន្តែបើកសិករចិញ្ចឹមទាយកសាច់ មិនចាំបាច់មានស្រះទឹកក៏បានដែរ។

ប៉ុន្តែអ្វីដែលសំខាន់នោះ គឺការរៀបចំចំណី។ ចំណីទាមិនពិបាករកទេ គ្រាន់តែការផ្គត់ផ្គង់ចំណីត្រូវឱ្យបានគ្រប់គ្រាន់។ ទាជាប្រភេទសត្វស៊ីចំណីច្រើន។ ទាទម្ងន់មួយគីឡូក្រាម គឺអាចស៊ីចំណី មួយគីឡូពីរខាំក្នុងមួយថ្ងៃ។ ចំណីរបស់ទាមានកន្ទក់ស្រូវ ស្លឹកកន្ទំថេត កំទេចកំទីបន្លែ ដើមចេក ឬជន្លេន-ល-។ ហើយទឹកសម្រាប់ទាផឹក ត្រូវតែមានជាប់ជាប្រចាំ ដាក់ក្នុងចានដែកមួយសម្រាប់ទាផឹក។ ហើយនៅក្នុងទឹកនោះ កសិករអាចដាក់ជាស្លឹកគ្រៃ ឬបណ្តូលពេជ្រ ស្តៅ ឬខ្ទឹមស ដែលគេចាត់ទុកជាថ្នាំបុរាណ ហើយទាផឹកទៅ អាចធន់នឹងជំងឺផ្សេងៗបាន។

លោកគីម ម៉េងសែ សំណូមពរថា បើចង់ចិញ្ចឹមទា កសិករគួរគប្បីស្វែងយល់អំពីបច្ចេកទេសចិញ្ចឹមឱ្យបានច្បាស់លាស់។ ហើយជាការប្រសើរដែរ ប្រសិនបើកសិករអាចចិញ្ចឹមទាកាប៉ាឱ្យបានច្រើន ព្រោះវាជាសត្វដែលងាយចិញ្ចឹមជាទីបំផុត គឺតាំងពីមិនសូវមានជំងឺ មិនសូវរើសចំណី លូតលាស់លឿន ហើយគុណភាពសាច់របស់វាក៏ល្អដែរ។

**បរិស្ថាន**

## ឧទ្យានជាតិវីរជ័យ

ឧទ្យានជាតិវីរជ័យ គឺជាតំបន់អាទិភាពមួយយ៉ាងសំខាន់សម្រាប់ធ្វើការអភិរក្សនៅក្នុងតំបន់អាស៊ី។ ឧទ្យានជាតិនេះគឺមានទីតាំងស្ថិតនៅក្នុងខេត្តរតនគិរី និងខេត្តស្ទឹងត្រែង នៅភាគឦសាននៃប្រទេសកម្ពុជា ដែលមានផ្ទៃដី៣៣២៥គីឡូម៉ែត្រក្រឡា។ នេះជាតំបន់ការពារ និងអភិរក្សព្រៃឈើ ធម្មជាតិ និងសត្វព្រៃគ្រប់ប្រភេទជាលក្ខណៈអន្តរជាតិ។



Photo: DR

ទឹកជ្រោះដែលហូរធ្លាក់ពីលើកំពូលភ្នំរបស់ឧទ្យានជាតិវីរជ័យផ្តល់ទឹកយ៉ាងសំខាន់សម្រាប់របបទឹកទន្លេមេគង្គ។ ប្រជាជនភាគច្រើនដែលរស់នៅក្នុងតំបន់ឧទ្យានជាតិ ជាជនជាតិភាគតិច។

ឧទ្យានជាតិវីរជ័យ បង្កើតឡើង ក្រោមព្រះរាជក្រឹត្យស្តីអំពីការបង្កើត និងរៀបចំនូវតំបន់ការពារធម្មជាតិចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ហើយគ្រប់គ្រងដោយក្រសួងបរិស្ថានប្រទេសកម្ពុជា។

នៅក្នុងឧទ្យានជាតិ មានវាលទំនាបដែលមានពណ៌បៃតងខៀវស្រងាត់ លាតសន្ធឹងស្មើរពាក់កណ្តាលផ្ទៃដីសរុប និងមានព្រៃឈើដុះពីលើភ្នំដេរដាស។ វាលស្មៅនៅខ្ពង់រាប ព្រៃគុម្ពឬស្សី និងព្រៃឈើដ៏ស្រស់ស្អាត និងគ្រប់ប្រភេទ ក៏ធ្វើឱ្យតំបន់ឧទ្យានជាតិនេះពេញដោយដំណាំបន្លែផ្លែផ្កាជាច្រើន។

កូនភ្នំ និងតំបន់ខ្ពង់រាបបានគ្របដណ្តប់ លើទីតាំងភូមិសាស្ត្រ ដែលមានរយៈកម្ពស់ នៅខ្ពស់ជាងទឹកសមុទ្រ៤០០ម៉ែត្រ ហើយបើនៅត្រង់ចំនុចព្រំដែនឡាវ និងវៀតណាម គឺមានរយៈកម្ពស់រហូតដល់១៥០០ម៉ែត្រ។ ចំណែកតំបន់វាលស្មៅ និងតំបន់ខ្យល់អាកាសបរិសុទ្ធ និងតំបន់វាលភក់ក៏ត្រូវបានគេរកឃើញផងដែរក្នុងឧទ្យានជាតិនេះ។

**ប្រែសម្រួលដោយថុង យ៉ត**



## សុខភាព

# ទទួលវ៉ាក់សាំងគឺឥតគិតថ្លៃ

**ជាន ភីរម្យ**

រាល់ការចាក់ថ្នាំវ៉ាក់សាំងបង្ការ ៧មុខ កំពុងអនុវត្តនៅក្នុងប្រទេសដោយឥតគិតថ្លៃ ហើយប្រជាជនក៏អាចទទួលបានសេវានេះ នៅគ្រប់មណ្ឌលសុខភាពនៅក្នុងខេត្តក្រុងនានា។ លោកសាន់ ច័ន្ទសឿន ជាប្រធានកម្មវិធីជាតិថ្នាំបង្ការ នៃក្រសួងសុខាភិបាល មានប្រសាសន៍ថា កុមារគឺអាចទទួលសេវាចាក់ថ្នាំបង្ការ ៧មុខ នៅតាមមណ្ឌលសុខភាពចំនួនជិត ១ពាន់កន្លែងនៅទូទាំងប្រទេស។

លោកក៏បានឱ្យដឹងថា : "វ៉ាក់សាំងទាំងនោះគឺមានវ៉ាក់សាំងប្រឆាំងជំងឺរបេង ជំងឺរលាកថ្លើមបេ ខាន់ស្លាក់ ក្អកមាន់ តេតាណូស កញ្ជ្រឹល និងជំងឺគ្រុនស្វិតដៃស្វិតជើង"។

លោកបានបញ្ជាក់ថា គ្រប់កុមារដែលកើតនៅតាមមណ្ឌលសុខភាពទាំងអស់ នឹងទទួលបានវ៉ាក់សាំងការពារជំងឺរបេង និងរលាកថ្លើមបេភ្លាម។ ក្រោយមកនៅពេលដែល ពួកគេមានអាយុ ៦អាទិត្យ ពួកគេក៏ទទួលវ៉ាក់សាំងការពារជំងឺខាន់ស្លាក់ ក្អកមាន់ និងតេតាណុស ក្នុងដំណាក់កាលទី១។ បន្ទាប់មកនៅពេលអាយុបាន ១០អាទិត្យ ពួកគេអាចទទួលវ៉ាក់សាំងជំងឺទាំងបីនាដំណាក់កាលទីពីរ ហើយនៅពេលដែលពួកគេមានអាយុ១៤អាទិត្យ អាចទទួលវ៉ាក់សាំងជំងឺដដែលដំណាក់កាលទីបី។ ចុងក្រោយនៅពេលដែលពួកគេមានអាយុ ៩ខែ គឺពួកគេអាចមកទទួលវ៉ាក់សាំងជំងឺកញ្ជ្រឹល។ ក្រៅពីនេះពួកគេក៏អាចទទួលវ៉ាក់សាំងជំងឺផ្សេងៗទៀតដែរ ដូចជាវ៉ាក់សាំងប្រឆាំងជំងឺស្វិតដៃជើង ហើយចំណែកស្ត្រីមានគភ៌ និងស្ថិតពេញវ័យបន្តពូជអាចទទួលនូវថ្នាំបំប៉នជីវជាតិ និងតេតាណូសផងដែរ។

លោកបញ្ជាក់ថា ដើម្បីឱ្យការផ្តល់វ៉ាក់សាំងនេះបានដល់កុមារគ្រប់ៗរូបទាំងអស់ រដ្ឋាភិបាលកម្ពុជា និងអង្គការម្ចាស់ជំនួយត្រូវការចំណាយថវិកាប្រមាណជាងបីលានដុល្លារ ក្នុងនោះរដ្ឋាភិបាលបានចំណាយថវិកាជាមធ្យមក្នុងមួយឆ្នាំ ១លានដុល្លារ ហើយចំណែកអង្គការសម្ពន្ធពិភពលោកដើម្បីវ៉ាក់សាំង និងថ្នាំបង្ការ ផ្តល់ជំនួយនូវជាថវិកាចំនួន២,៣លានដុល្លារនៅក្នុង១ឆ្នាំៗ ដើម្បីជួយកម្ពុជា"។



កម្មវិធីជាតិផ្តល់ថ្នាំបង្ការ

លោកបានបន្តទៀតថា ក្រៅពីវ៉ាក់សាំងទាំង ៧មុខនេះ កម្ពុជាក៏គ្រោងនឹងបន្ថែមវ៉ាក់សាំង ជំងឺរលាកស្រោមខួរ ក្នុងកម្មវិធីជាតិថ្នាំបង្ការផងដែរ ដោយផែនការនេះ ត្រូវបានគេរំពឹងថា នឹងទទួលបាននៅចុងឆ្នាំ២០០៩ ឬដើមឆ្នាំ២០១០ខាងមុខ។

## ខួប ៦០ឆ្នាំ នៃអង្គការ OMS

**ភ័យអំពីការប្រែប្រួលអាកាសធាតុ**

**ហ្សឺណែវ(AFP)-អង្គការសុខភាពពិភពលោក OMS លើកយកការផ្លាស់ប្តូរអាកាសធាតុធ្វើជាប្រធានបទនៅទិវាសុខភាពពិភពលោក ដែលនៅឆ្នាំនេះជាខួបកំណើត ទី៦០ របស់ខ្លួន។ អង្គការអំពាវនាវឱ្យចាត់វិធានការបន្ទាន់ដើម្បីប្រឆាំងនឹងការកើនកម្តៅនៃផែនដីដែលហុចផលវិបាកដោយផ្ទាល់ចំពោះសុខភាពមនុស្ស។ បាតុភូតនេះបណ្តាលឱ្យខូចខាតគុណភាពទឹកដែលជាកត្តាងាយស្រួលបណ្តាលឱ្យមានជំងឺរាគរូស។ ការកើនឡើងនូវភ្លៀង និងសីតុណ្ហភាពមានឥទ្ធិពល ដល់ការរីកសាយភាយនូវជំងឺគ្រូពិចដូចជាជំងឺគ្រុនឈាម និងគ្រុនចាញ់ដែលចម្លងដោយសារមូសផងដែរ។ រយៈពេល ៣ឆ្នាំ កន្លងមកហើយ អង្គការសុខភាពពិភពលោក បានព្រមានថា ការកើនកម្តៅអាកាសធាតុបានបណ្តាលឱ្យមនុស្ស ១៥០ ០០០នាក់ស្លាប់ និង ៥លាននាក់ទៀត ឈឺជារៀងរាល់ឆ្នាំ។**

## ជំងឺមហារីកឆ្អឹង




Photo: P. Samphy

លោកដួង ប៊ុណ្ណ ជាវេជ្ជបណ្ឌិតឯកទេសខាងជំងឺឆ្អឹងប្រចាំនៅមន្ទីរពេទ្យព្រះកុសុមៈ (ហៅពេទ្យលោកសង្ឃ) បានមានប្រសាសន៍ឱ្យដឹងថា:

មហារីកឆ្អឹងគឺនិយាយអំពីដុំរបស់ឆ្អឹង។ ដុំរបស់ឆ្អឹងចែកចេញជាពីរប្រភេទ មានដុំស្លូត និងដុំកាច។ ដុំស្លូត ចែកចេញជាច្រើនប្រភេទទៀត ដូចជាដុំស្លូតគ្មានសកម្មភាព ដុំស្លូតមានសកម្មភាព ហើយនិងដុំស្លូតរាលដាល។ ដុំស្លូតគ្មានសកម្មភាព គឺមិនបង្កឱ្យមានគ្រោះថ្នាក់ទេ។ តែដុំស្លូតមានសកម្មភាព និងរាលដាល វាអាចវិវត្តទៅជាជំងឺមហារីក បើកាលណា យើងទុកវាយូរដោយគ្មានការព្យាបាល។

ចំណែកដុំកាច គឺដុំមហារីកតែម្តង។ វាគឺមានច្រើនប្រភេទទៀត គឺមហារីកឆ្អឹងដែលកើតពីឆ្អឹងខ្លួនឯង ឬមហារីកឆ្អឹង ដែលរាលមកពីមហារីកកន្លែងដទៃ មាន មហារីកដោះ មហារីកសួត មហារីកប្រូស្តាត (ក្រពេញទឹកកាមមនុស្សប្រុស)-ល-។

ដើម្បីឱ្យដឹងថា ឆ្អឹងគឺជាមហារីកយ៉ាងម៉េច ទីមួយគឺត្រូវពិនិត្យ ទីពីរធ្វើការថតឆ្លុះ និងទីបី ការពិនិត្យធ្វើ **Histology** គឺមន្ទីរពិសោធន៍ គេយកឆ្អឹងទៅវិភាគ។ ក្រោយពីពិនិត្យគ្រូពេទ្យនឹងដឹងថា វាគឺជាដុំកាចប្រភេទណា កម្រិតណា និងវាអាចវិវត្តន៍ទៅដល់កម្រិតណា រួចទើបព្យាបាលតាមក្រោយ។

នៅពេលអ្នកជំងឺមានដុំមហារីកឆ្អឹង ឆ្អឹងឡើងប៉ោង អ្នកជំងឺមានការឈឺចាប់ ហេវហត់ ក្តៅខ្លួន ពុំឃ្លានបាយ ពុំឃ្លានទឹក ស្លេកស្លាំង ឈាមក្រហមចុះ និងឈាមសឡើង ហើយអាចរាលដាល ទៅដល់សរីរាង្គផ្សេង ធ្វើឱ្យខូចតម្រងនោម ខូចសួត ខួរក្បាល ដែលជាអាការៈធ្ងន់ធ្ងរ និងធ្វើឱ្យអ្នកជំងឺស្លាប់។

ការព្យាបាលជំងឺមហារីកឆ្អឹង មានបីប្រភេទសំខាន់ៗ ទីមួយ ការវះកាត់ដែលជាប្រភេទចម្បងគេ។ ទីពីរ គឺការព្យាបាលគីមី និងទីបី ជាការការព្យាបាលដោយវិទ្យុសកម្ម។ ការព្យាបាលគឺត្រូវធ្វើឡើងជាមួយវេជ្ជបណ្ឌិតជំនាញៗ និងក្នុងដំណាក់កាលរោគសញ្ញាដំបូងទើបសង្ឃឹមជាសះស្បើយ។

April-2008.qxd 5/2/2008 11:29 AM Page 14

## ប្រពៃណី



Photo : L. Sovanna

បុណ្យចម្រើនព្រះជន្ម ខុសពីពិធីខួបកំណើត

# តើបុណ្យខួបកំណើតជាបុណ្យចម្រើនព្រះជន្ម?

**ជាន ភិរម្យ**

អ្នកស្រាវជ្រាវមួយរូប អះអាងថា បុណ្យចម្រើនព្រះជន្ម ជាព្រះរាជពិធីសម្រាប់ព្រះមហាក្សត្រ ដែលត្រូវបានរៀបចំឡើង ជារៀងរាល់ឆ្នាំ តែចំពោះប្រជារាស្ត្រសាមញ្ញ គឺគេកម្រនឹងរៀបចំណាស់។

ពិធីបុណ្យចម្រើនព្រះជន្មនេះ គេហៅបានតែចំពោះព្រះមហាក្សត្រ ឬព្រះសង្ឃប៉ុន្តែសម្រាប់ប្រជារាស្ត្រសាមញ្ញ គេច្រើនហៅថា ពិធីបុណ្យចម្រើនអាយុ។

លោកព្រាប ច័ន្ទម៉ារ៉ា អ្នកស្រាវជ្រាវនៅអង្គការរ៉ែយំ អះអាងដែរថា: "ចំពោះពិធីបុណ្យចម្រើនអាយុ ឬក៏បុណ្យចម្រើនព្រះជន្មនេះ គេគឺកម្រឃើញប្រជារាស្ត្រកម្ពុជាសាមញ្ញរៀបចំឡើង ជារៀងរាល់ឆ្នាំណាស់ គឺលើកលែងតែព្រះមហាក្សត្រ ដោយសារព្រះអង្គជាបុគ្គលសំខាន់នៃជាតិ។ សម្រាប់ប្រជារាស្ត្រធម្មតា គេច្រើនរៀបចំពិធីនេះនៅពេលពួកគេឈានចូលដល់វ័យចំណាស់ ឬមានបញ្ហាសុខភាពដោយសារប្រការណាមួយ។ ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ឬបុណ្យចម្រើនអាយុនេះ ជាពិធីបុណ្យមួយក្នុងចំណោម ពិធីបុណ្យឆ្លងវ័យទាំងឡាយ ដែលមនុស្សខ្មែរបុរាណរៀបចំឡើង ដើម្បីគោរពទៅតាមច្បាប់ធម្មជាតិ"។

បុណ្យឆ្លងវ័យ មាន៧ដំណាក់កាល គឺពេលកើត ហៅថាពិធីបុណ្យកាត់សក់បង្កក់ឆ្នប។ ដំណាក់កាលទីពីរ គឺពិធីកោរជប់។ ដំណាក់កាលទីបី គឺពិធីចូលម្លប់សម្រាប់មនុស្សស្រី ឬបួសរៀនសម្រាប់ប្រុស។ ដំណាក់កាលទីបួន គឺពិធីមង្គលការ។ ដំណាក់កាលទី៥ គឺពិធីប្រែជាម្តាយ និងឪពុក។ ដំណាក់កាលទី៦ គឺពិធីបុណ្យចម្រើនអាយុ និងដំណាក់ទី៧ គឺពិធីបុណ្យសព ។

លោកច័ន្ទម៉ារ៉ាបានបន្ថែមទៀតថា បើតាមប្រពៃណី ប្រជារាស្ត្រខ្មែរបុរាណ តែងរៀបចំពិធីឆ្លងវ័យរបស់ពួកគេ ហើយចំពោះពិធីបុណ្យចម្រើនអាយុ ឬក៏ព្រះជន្មនេះវិញ គេនិយមរៀបចំឡើងនៅពេលមានវ័យចាស់ក្នុងគោលបំណងចង់កែប្រែច្បាប់ធម្មជាតិ ចង់ឱ្យនៅក្មេង។ នៅក្នុងពិធីនេះ គឺគេមានរៀបចំឧបកិច្ច ឱ្យអ្នកដែលគេរៀបចំពិធីឱ្យធ្វើជាស្លាប់ រួចកើតឡើងវិញនៅក្នុងគោលបំណងឱ្យបុគ្គលនោះជួបនូវអ្វីដែលថ្មី ។

តាមការគ្រោងទុក ព្រះមហាក្សត្រកម្ពុជាគ្រោងនឹងរៀបចំ ពិធីបុណ្យចម្រើនព្រះជន្មរបស់ព្រះអង្គ រយៈពេល៣ថ្ងៃ ដោយចាប់ផ្តើមធ្វើពីថ្ងៃទី១៣ រហូតដល់ថ្ងៃទី១៥ ខែឧសភា ខាងមុខនេះ ។

## អំណាន

### មហាចោរនៅទល់ដែន




ជាកម្រងប្រលោមលោកដ៏សម្បូរបែប និងជាស្នាដៃនិពន្ធដែលប្រកបទៅដោយទេពកោសល្យរបស់លោកសាង សាវ៉ាត។

រឿងនេះនិយាយអំពីវីរភាពនៃកូនខ្មែរដែលប្រាថ្នាចង់បានឯករាជ្យជាតិ និងភាពយុត្តិធម៌ជូនដល់ជនជាតិខ្មែរ ដែលរស់ក្នុងបណ្តាខេត្តដែលសៀមកាន់កាប់អំឡុងឆ្នាំ១៨៦៥។ រឿងដ៏រស់រវើកនេះមានបង្កប់នូវចំណងបញ្ហាចាក់ស្រេះជាច្រើនជំពូក មានទាំងមនោសញ្ចេតនាស្នេហា មិត្តភាព និងគំនុំចងអាឃាត-ល-។ ចំណុចពិសេស ដ៏គួរឱ្យកោតសរសើរមួយទៀត របស់អ្នកនិពន្ធ គឺលោកបានសិក្សាវិភាគចិត្តសាស្ត្រ ព្រមទាំងបញ្ហារបស់មនុស្ស។ ដូច្នេះហើយទើបតួអង្គរបស់គាត់ គឺសុទ្ធតែមានលក្ខណៈជាមនុស្សដ៏ពិតប្រាកដ គឺចេះស្រលាញ់ ចេះស្អប់ មានចាញ់ មានឈ្នះ មានខុស និងត្រូវ... តាមរយៈអំណានរឿងមហាចោរនៅទល់ដែននេះ យើងនឹងបានដឹងអំពីជីវភាពរស់នៅរបស់មនុស្សនាសម័យនោះ ព្រមទាំងសប្បាយរីករាយនឹងសំនួនវោហារដ៏ប៉ិនប្រសប់ របស់អ្នកនិពន្ធ។ រឿងនេះមានកម្រាស់ ២៣១ទំព័រ។

### រាជិនីគោកធ្លក




ជាប្រលោមលោក ដែលនិពន្ធឡើងដោយពឹងផ្អែកលើរឿងព្រេងបែបប្រវត្តិសាស្ត្រ នៃព្រះរាជាណាចក្រកម្ពុជាយើង។ ក្នុងរឿងនេះ លោកសាំង ហ៊ែល បាននាំអ្នកអាន ទាំងអស់ឱ្យត្រលប់ទៅរកអតីតកាលនាសម័យមុនគ្រិស្តសករាជ ដែលវេលានោះ ប្រទេសខ្មែរនៅជាដែនកោះគោកធ្លកនៅឡើយ។

បើតាមសាច់រឿង អ្នកអាននឹងកោតស្ញប់ស្ញែងចំពោះភាពអង់អាចក្លាហាន ការបូជាកម្លាំងកាយ-ចិត្ត ចំពោះកោះគោកធ្លក និងសេចក្តីស្នេហាស្មោះត្រង់នៃគូសង្សារមួយគូ គឺនាងសក់ក្រអូប និងបាយ៉ង់ដែលជាតួអង្គឯកក្នុងរឿង។ សិល្បវិធីដ៏ប៉ិនប្រសប់នៃអ្នកនិពន្ធក៏បានធ្វើឱ្យដំណើររឿងនេះមានភាពប្រទាក់ក្រឡាគ្នានិងព្រមទាំងធ្វើឱ្យអ្នកអានស្លុងអារម្មណ៍ទៅនឹងព្រឹត្តិការណ៍នានា ដែលតួអង្គកំពុងតែជួបប្រទះ និងប្រឈមមុខ។ ក្រៅពីនេះរាជិនីគោកធ្លកក៏មានបង្កប់នូវផ្នត់គំនិតប្រពៃណី ព្រមទាំងជំនឿផ្សេងៗរបស់ជនជាតិខ្មែរ នៅសម័យនោះផងដែរ។ រឿងនេះមានកម្រាស់១២៧ទំព័រ និងលក់ក្នុងតម្លៃ ៣០០០រៀល។

**ម៉េង សុមនា**



## ប្រវត្តិសាស្ត្រ

# ទីបេ ប្រវត្តិសាស្ត្រក្រោមឥទ្ធិពលរបស់ចិន

**អាន ឡូរ៉ី ប៉ូរ៉េ**

ប្រវត្តិសាស្ត្ររបស់ទីបេ អាស្រ័យទៅនឹងទីតាំងភូមិសាស្ត្ររបស់ខ្លួន។ ដោយវាស្ថិតនៅលើរយៈកម្ពស់ខ្ពស់ និងខ្វះផ្លូវគមនាគមន៍ តំបន់ទីបេចៀសផុតពីការលុកលុយជាច្រើន។ តំបន់នេះក៏មានជ្រលងភ្នំច្រើន និងស្ថិតនៅដាច់ៗពីគ្នាដែលបង្កឱ្យមានមជ្ឈមណ្ឌលអំណាចនៅដាច់ៗពីគ្នាដែរ ហើយប្រជាជនរស់នៅដោយប្រកបរបរកសិកម្ម។ តំបន់នេះទើបត្រូវបានរួបរួមពិតប្រាកដនាចុងសតវត្សរ៍ទី៦ និងដើមសតវត្សរ៍ ទី៧។ ក្នុងរាជ្យនៃព្រះអង្គសុងសេនហ្គាំប៉ូ (Songtsen Gampo) ឡាសា (Lhasa) បានក្លាយជារាជធានីរដ្ឋបាលរបស់ទីបេ។ នៅសម័យនោះ អក្សរទីបេត្រូវបានបង្កើតឡើង ហើយទំនាក់ទំនងជាមួយនិងប្រទេសចិន ក៏បានចាប់ផ្តើមឡើងផងដែរ។ ទោះជាយ៉ាងណាតំបន់ទីបេនេះ ឆ្លងកាត់ពេលវេលាដោយឋិតនៅក្រោមឥទ្ធិពលនៃវប្បធម៌របស់ប្រទេសឥណ្ឌា។ ហើយព្រះពុទ្ធសាសនាក្លាយជាសាសនាព្រះរាជាណាចក្រនៅឆ្នាំ៧៧៩។

អំឡុងជាច្រើនសតវត្សរ៍ ទីបេក៏បានប្រទះសង្គ្រាមដណ្តើមរាជ្យ និងក៏មានការប្រឡងប្រជែងគ្នារវាងអំណាចរាជានិយម និងនាយករដ្ឋមន្ត្រី រវាងរាជាធិបតេយ្យ និងវណ្ណៈអភិជន រវាងក្រុមគណៈកាន់ព្រះពុទ្ធសាសនា និងទាយាទនៃប្រពៃណីសាសនាដ៏យូរលង់ប្រចាំក្នុងតំបន់។

នៅសតវត្សរ៍ទី១១ ព្រះពុទ្ធសាសនាបានរីកចម្រើនយ៉ាងខ្លាំង។ វត្តអារាមព្រះពុទ្ធសាសនាក៏បានសាងសង់សាលាពុទ្ធិកសិក្សាជាច្រើន និងមានកម្មសិទ្ធិដីធ្លីច្រើន ដែលធ្វើឱ្យវត្តអារាមក្លាយជាមជ្ឈមណ្ឌលអំណាច។ ចាប់តាំងពីពេលនោះជីវភាពនយោបាយទីបេអាស្រ័យនឹងជីវិត ក្នុងវត្តអារាមពុទ្ធសាសនា។ម្យ៉ាងទៀតភាសាទីបេមិនមានពាក្យសម្រាប់ ហៅពុទ្ធសាសនិកឡើយ គឺមានតែពាក្យ "មនុស្សខាងក្នុង"។ តួយ៉ាងបើជនជាតិទីបេ ដែលកាន់សាសនាឥស្លាមគេហៅគាត់ថា "មនុស្សខាងក្រៅ" ពីព្រោះគាត់មិនកាន់ព្រះពុទ្ធសាសនា។

តាមធម្មតា បក្សដែលកាន់អំណាច គឺរក្សាអំណាចនោះដោយមានការគាំទ្រអំពីអំណាចបរទេសណាមួយ។ ក្រោមការត្រួតត្រា របស់ម៉ុងហ្គោល (នៅសតវត្សរ៍ទី១៦) អ្នកកាន់អំណាចកំពូលទីបេ ត្រូវបានប្រសិទ្ធនាមហៅថា "ដាឡៃ ឡាម៉ា" **"dalaï-lama"**។ តែនាមដែលមានន័យស្មើនឹងអាទិទេព ឬ"សមុទ្រគុណធម៌"នេះ ជួនកាល ក៏បង្កឱ្យមាននូវការប្រណាំងប្រជែងដណ្តើមអំណាចរវាងមេដឹកនាំសាសនាធំៗផងដែរ។ ប្រទេសចិនក្រសោបយក ទីបេនៅសតវត្សរ៍ទី១៨ ដើម្បីបញ្ចៀសតំបន់នោះ កុំឱ្យធ្លាក់ក្រោមឥទ្ធិពលនៃប្រទេសផ្សេងទៀត។

នៅសតវត្សរ៍ទី២០ ទំនាក់ទំនងជាមួយចិន គឺមិនល្អទេ។ នៅឆ្នាំ១៩៥១ ទីបេត្រូវបានភ្ជាប់ទៅនឹងចិន កុំម្មុយនីស្ត ដែលគេបានគ្រប់គ្រងលើកម្លាំងយោធា ហិរញ្ញវត្ថុ ការសិក្សាអប់រំ និងសេដ្ឋកិច្ច...។ ដាឡៃ ឡាម៉ា លុបចោលនូវប្រព័ន្ធកំណែនសក្តិភូមិ បំណុលកម្មសិទ្ធិដីធ្លី និងបង្កើតគម្រោងបែងចែកដីធ្លីសាជាថ្មី។ ប៉ុន្តែការលូកដៃរបស់ចិនបានប៉ះពាល់ទៅដល់ប្រជាជន ដែលពុំព្រមចុះចូលដោយស្ងៀមស្ងាត់ ហើយរត់ទៅធ្វើទ័ពព្រៃ។ ប៉ុន្តែការបង្ក្រាបបានជំរុញឱ្យជនជាតិទីបេជាច្រើនធ្វើនិរទេសខ្លួនជាមួយអ្នកដឹកនាំរបស់ពួកគេ។ ដោយធ្វើការបរិហារចំពោះនយោបាយធ្វើអាណានិគមលើប្រជាជនខ្លួន ដាឡៃ ឡាម៉ា ស្វែងរកការគាំទ្រជាលក្ខណៈអន្តរ-ជាតិ។ ប្រតិកម្មជាក់ស្តែង តែមិនញឹកញាប់ ក៏មិនធ្វើឱ្យទន់ខ្សោយដល់អំណាចរបស់ចិនឡើយ។




Photo : DR

### នរណាជាដាឡៃ ឡាម៉ា?



Photo : DR

តេងស៊ីន ហ្យ៊ីអាសូ Tenzin Gyatso ជាដាឡៃឡាម៉ាទី១៤ មានន័យថាជាមេដឹកនាំដួងព្រលឹង និងអាណាចក្រទីបេ។ ប្រសូតនៅឆ្នាំ១៩៣៥ កូនកសិកររូបនេះត្រូវបានគេទទួលស្គាល់តាំងពីអាយុ ២ឆ្នាំ ថាជាដាឡៃ ឡាម៉ា ទី១៣ ចាប់ជាតិ។ ព្រះអង្គបានរៀនសូត្រធម៌នៅវត្តអារាមតាំងពីអាយុ ៦ឆ្នាំ និងក្លាយជាប្រមុខរដ្ឋាភិបាលនៅអាយុ ១៥ឆ្នាំ។ នៅឆ្នាំ១៩៥៩ នៅឥណ្ឌា អាជ្ញាធរចិនគិតចង់ចាប់ខ្លួនលោក បន្ទាប់ពីលោកបានរស់នៅក្នុងភាពនិរទេសខ្លួន។ ចាប់តាំងពី ឆ្នាំ១៩៧៩ លោកលែងប្រកាសឯករាជ្យភាពទៀតហើយ ប៉ុន្តែទីបេមានស្វ័យតភាព (ដោយហេតុថា រដ្ឋាភិបាលចិនបានប្រកាសថាពិភាក្សាក្នុងរឿងនេះ)។ លោកបានទទួលពានរង្វាន់ណូបែលសន្តិភាពនៅឆ្នាំ១៩៨៩។

# ល្បែងកំសាន្ត

## ភ្ជាប់រូប

សូមប្អូនៗ សាកភ្ជាប់តាំងពីលេខ១ ដល់លេខ៣១ ប្អូនៗនឹងឃើញថា ផេងកំពុងតែស្រមៃពីអ្វីហើយ។




## ល្បែងគិតលេខ

ចូរសាកល្បងគណនាលេខ ដែលនៅជិតរូបសត្វខាងក្រោម រួចផាត់ពណ៌សត្វទាំងនេះតាមពណ៌ចម្លើយ ដែលបានរកឃើញ។




ចម្លើយ : ទំព័រ៣

សូមថ្លែងអំណរគុណចំពោះអង្គការស៊ីតា

## ការងារប្រចាំខែ

- នៅក្នុងខែមេសា : យុវជននៅព្រះសហគមន៍កាតូលិកកោះរកាខេត្តកំពង់ចាមចំនួន ២៦នាក់ ចុះសួរសុខទុក្ខយុវជននៅខេត្តមណ្ឌលគិរី ដើម្បីបង្កើនភាពជិតស្និទ្ធ និងទំនាក់ទំនងមិត្តភាព។
- ជារៀងរាល់ថ្ងៃអាទិត្យ : កុមារអាយុពី៨-១២ឆ្នាំចំនួន៣៥នាក់ នៅព្រះសហគមន៍អ្នកលឿងភូមិភាគកំពង់ចាមកំពុងទទួលការអប់រំអំពីអគ្គ-សញ្ញាទទួលព្រះកាយព្រះគ្រីស្ត។
- ថ្ងៃទី០៩ មេសា : នៅព្រះសហគមន៍កាតូលិកខេត្តកំពង់ចាមមានការរៀបចំនូវកិច្ចប្រជុំអន្តរ-និកាយសាសនាគ្រីស្ត។
- ឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ : លោកបូជាចារ្យហ្វ្រង់កូ អ្នកទទួលបន្ទុកនៅព្រះសហគមន៍ខេត្តកំពង់ធំ មានរៀបចំជំនួបជាមួយនិងកម្មករ-ការិនីរោងចក្រ (អតីតយុវជនរបស់ព្រះសហគមន៍កាតូលិក) ដើម្បីចែកចាយបទពិសោធន៍គ្នាទៅវិញទៅមកក្នុងជីវិតរស់នៅ។
- ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ : នៅតាមព្រះសហ-គមន៍កាតូលិកនានានៅទូទាំងប្រទេសកម្ពុជា មានរៀបចំប្រារព្ធពិធីដើម្បីអបអរសាទបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។
- នៅថ្ងៃទី១៣ មេសា : ព្រះសហគមន៍កាតូលិកនៅក្រុងព្រះសីហនុ រៀបចំកម្មវិធីស្រោចទឹកជូនមនុស្សចាស់ៗប្រហែល៥០នាក់ ដែលមកពីព្រះសហគមន៍ផ្សេងៗ ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ។
- ថ្ងៃទី២៧ មេសា : លោកអេមីល ដេតម្ប ជាអភិបាលនៃភូមិភាគភ្នំពេញ ធ្វើពិធីលាបថ្វាសដល់អ្នកទទួលអគ្គសញ្ញាជ្រមុជទឹក ចំនួន២២នាក់ នៅព្រះសហគមន៍កាតូលិកជុំគិរី ខេត្តកំពត។ ក្នុងថ្ងៃនោះដែរ លោកអភិបាលអេមីល ដេតម្ប ក៏ចុះទៅធ្វើការសាកសួរសុខទុក្ខបងប្អូនជាគ្រីស្ត-បរិស័ទទាំងអស់នៅខេត្តកំពត។
- ថ្ងៃទី២៨ មេសា : ព្រះសហគមន៍កាតូលិកកំពង់ចាមមានរៀបចំនូវអង្គសិក្ខាសាលាមួយអំពីបច្ចេកទេសកសិកម្មខាងការចិញ្ចឹមមាន់ដល់បងប្អូនគ្រីស្តបរិស័ទ។
- ថ្ងៃទី១៣ ដល់១៥ ខែឧសភា : សិក្ខាសាលាគ្រូអប់រំបន្តជំនឿទាំងបីភូមិភាគនៅព្រះសហ-គមន៍កាតូលិកខេត្តកំពង់ចាម។
- ថ្ងៃទី១៤ ដល់១៥ ខែមិថុនា : សិក្ខាសាលាគ្រូអប់រំបន្តជំនឿនៅភ្នំពេញអំពីគម្ពីរសម្ពន្ធមេត្រីចាស់ (ត) ដែលរៀបចំ និងទទួលខុសត្រូវដោយមណ្ឌលវប្បធម៌កាតូលិក និងលោកអ៊ំត អ៉យ។